ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៦៣ ត្រីមាសទី០៣ ឆ្នាំ២០២១

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៨-១១-២០២១	-ព្រះរាជក្រម នស/រកម/១១២១/០១៨ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ភាពជាដៃគូរវាងរដ្ឋ និងឯកជន	៧៧៤១

២~ព្រះរាជក្រឹត្យ

៣-១១-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៧១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ស៊ុង អ៊ីនម៉ូ (SUNG INMO)** ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ ដោយប្តូរឈ្មោះជា **ស៊ុង សែន (SUNG SEN)**	៧៧៧០
៣-១១-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៧២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឈិន ឈានជីន (CHEN QUAN JIN)** ជនជាតិចិន សញ្ជាតិចិន	៧៧៧១
៣-១១-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៧៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ថាំង វ៉េម៉ៅ (TANG, WEIMAO)** ជនជាតិចិន សញ្ជាតិចិន	៧៧៧២
៣-១១-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៧៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក និងលោកស្រី ចំនួន ៦៦ រូប	៧៧៧៣
៣-១១-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៧៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឧកញ៉ា លោកជំទាវ អស់លោក និងលោកស្រី ចំនួន ៦៤ រូប	៧៧៧៥
៥-១១-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៧៦ ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងលោកជំទាវ **ហូ សុវណ្ណិកា** ពីរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ មកជារដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	៧៧៧៧
៥-១១-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១១២១/៧៧៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឈិន ប៉លីន (CHEN BOLIN)** ជនជាតិចិន សញ្ជាតិចិន	៧៧៧៨

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១-១១-២០២១	-អនុក្រឹត្យលេខ ២០៩ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា	៧៧៧៩
៣-១១-២០២១	-អនុក្រឹត្យលេខ ២១២ អនក្រ.បក ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការពិសេសតាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍	៧៧៨១
៥-១១-២០២១	-អនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា	៧៧៨៦

៥-១១-២០២១ -អនុក្រឹត្យលេខ ៥១៧ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧៧៩៨

៥-១១-២០២១ -អនុក្រឹត្យលេខ ៥១៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧៧៩៩

៥-១១-២០២១ -អនុក្រឹត្យលេខ ៥១៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧៨០៣

១០-១១-២០២១ -អនុក្រឹត្យលេខ ៥២០ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៧៨០៥

១០-១១-២០២១ -អនុក្រឹត្យលេខ ៥២១ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៧៨០៧

១០-១១-២០២១ -អនុក្រឹត្យលេខ ៥២២ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៧៨០៩

១០-១១-២០២១ -អនុក្រឹត្យលេខ ៥២៣ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៧៨១១

២~សេចក្ដីសម្រេច

១៧-១១-២០២១ -សេចក្ដីសម្រេចលេខ ១១២ សសរ ស្ដីពី ការតែងតាំងអនុប្រធានក្រុមការងាររាជរដ្ឋាភិបាល ចុះមូលដ្ឋានរាជធានីភ្នំពេញ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ៧៨១៣

២៤-១១-២០២១ -សេចក្ដីសម្រេចលេខ ១១៣ សសរ ស្ដីពី ការបញ្ចូលក្របខ័ណ្ឌពលទាហានថ្មី ៧៨១៥

III~ការងារបណ្ដាក្រសួង

១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៣-៣-២០២១ -ប្រកាសលេខ ១៨៦ សហវ.ប្រក ស្ដីពី ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនប្រធាន អង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៧៨១៦

២៩-៣-២០២១ -ប្រកាសលេខ ១៩៥ សហវ.ប្រក ស្ដីពី ការបង្កើតសារមន្ទីរគយ ៧៨១៩

២៩-៣-២០២១ -ប្រកាសលេខ ១៩៦ សហវ.ប្រក ស្ដីពី វិធាន និងនីតិវិធីនៃការព្យួរការបំពេញបែបបទបញ្ចេញ ទំនិញពីគយចំពោះទំនិញនាំចេញ-នាំចូលល្មើសកម្មសិទ្ធិបញ្ញា ៧៨២២

៣១-៣-២០២១ -ប្រកាសអន្តរក្រសួងលេខ ១៩៩ សហវ.ប្រក ស្ដីពី ការតែងតាំងភ្នាក់ងារបើកផ្ដល់ នៅវិទ្យាស្ថាន ស្រាវជ្រាវកៅស៊ូកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៧៨២៨

២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

១៦-២-២០២១ -ប្រកាសលេខ ០៧៤ ឧវបន.កឧ.ប្រក ០២ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មេគង្គ ហ្រ្គីន ហ្វាម បង្កើតរោងចក្រ កែច្នៃជ័រកៅស៊ូ ៧៨៣១

១៦-២-២០២១ -ប្រកាសលេខ ០៧៥ ឧវបន.កឧ.ប្រក ០២ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេវ៉ាយស៊ី ហ្គាម៉ិន ហ្វេកធើរី ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៧៨៣៤

១៧-២-២០២១ -ប្រកាសលេខ ០៧៧ ឧវបន.កឧ.ប្រក ០២ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីធី ព្រីនធីង (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតប្រអប់ក្រដាសកាតុង និងផលិតផលវេចខ្ចប់ពី ក្រដាសគ្រប់ប្រភេទ ៧៨៣៧

១៨-២-២០២១	-ប្រកាសលេខ ០៧៩ ឧវបន.កឧ.ប្រក ០២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ុន ស៊ីន ឡាក់ ហ្គេដ អ៊ិនដាសស្ទ្រី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូប និងកាបូបក្លាសេគ្រប់ប្រភេទ	៧៨៤០
២៣-២-២០២១	-ប្រកាសលេខ ០៨១ ឧវបន.កឧ.ប្រក ០២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីប ម៉ុង អ៊ិនស៊ីស៊ីមេន ខបភើរេសិន បង្កើតរោងចក្រ ផលិតស៊ីម៉ងត៍	៧៨៤៣
២៤-២-២០២១	-ប្រកាសលេខ ០៨៣ ឧវបន.កឧ.ប្រក ០២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេវើរគ្រីន ហ្គាមេនខូ អេលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់	៧៨៤៦

៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

២១-១០-២០២០	-ប្រកាសលេខ ០៤៦៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៦៥ រថ.អប្រក.លអ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០	៧៨៤៩
២១-១០-២០២០	-ប្រកាសលេខ ០៤៦៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៦៦ រថ.អប្រក.លអ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០	៧៨៥៣
២១-១០-២០២០	-ប្រកាសលេខ ០៤៦៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៦៧ រថ.អប្រក.លអ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០	៧៨៥៧
២១-១០-២០២០	-ប្រកាសលេខ ០៤៦៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៦៨ រថ.អប្រក.លអ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០	៧៨៦១
២១-១០-២០២០	-ប្រកាសលេខ ០៤៦៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៦៩ រថ.អប្រក.លអ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០	៧៨៦៥
២១-១០-២០២០	-ប្រកាសលេខ ០៤៧០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៧០ រថ.អប្រក.លអ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០	៧៨៦៩
២១-១០-២០២០	-ប្រកាសលេខ ០៤៧១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៧១ រថ.អប្រក.លអ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០	៧៨៧៣
២១-១០-២០២០	-ប្រកាសលេខ ០៤៧២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៤៧២ រថ.អប្រក.លអ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២០	៧៨៧៧

ព្រះរាជក្រម

យើង

នស/រកម/១១២១/០១៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់

ស្តីពី

ភាពជាដៃគូរវាងរដ្ឋនិងឯកជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ច្បាប់នេះមានគោលបំណងលើកកម្ពស់ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន សរសេរជាអក្សរកាត់ថា ភ.រ.ជ. ក្នុងការរៀបចំ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងគម្រោងសេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ចីរភាព តម្លាភាព គណនេយ្យភាព និងយុត្តិធម៌ ដើម្បីជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម នៅព្រះរាជាណាចក្រកម្ពុជា ដោយ៖

- កំណត់ស្ថាប័នមានសមត្ថកិច្ចសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងភ.រ.ជ. ជាលក្ខណៈប្រព័ន្ធ
- បង្កើតក្របខ័ណ្ឌដើម្បីអភិវឌ្ឍ អនុវត្ត គ្រប់គ្រង និងតាមដានត្រួតពិនិត្យគម្រោងភ.រ.ជ.
- បង្កើតវិធាន វិធីសាស្ត្រ នីតិវិធី និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្មក្នុងក្របខ័ណ្ឌគម្រោងភ.រ.ជ.
- កំណត់យន្តការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោងភ.រ.ជ.។

មាត្រា២ .-

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងលើការអភិវឌ្ឍនិងការអនុវត្តគម្រោងភ.រ.ជ. ក្នុងវិស័យមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្របតាមមាត្រា៨នៃច្បាប់នេះ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិង/ឬផ្តល់សេវាសាធារណៈ។

មាត្រា៣ .-

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់នៅក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ១នៃច្បាប់នេះ។

ជំពូកទី២
ស្ថាប័នមានសមត្ថកិច្ច

មាត្រា៤ .-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាស្ថាប័នមានសមត្ថកិច្ចក្នុងការដឹកនាំនិងគ្រប់គ្រងយន្តការ ភ.រ.ជ.នៅព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីនិងភារកិច្ចជាអាទិ៍៖

- ជាសេនាធិការនិងជា"ច្រកចេញចូលតែមួយ"របស់រាជរដ្ឋាភិបាល ក្នុងការទទួលបន្ទុកគម្រោងភ.រ.ជ. ក្នុងគ្រប់ដំណាក់កាលនៃវដ្តគម្រោង។

២- ស្នើឡើងនូវគោលនយោបាយអភិវឌ្ឍន៍យន្តការភ.រ.ជ. និងដឹកនាំការរៀបចំបទប្បញ្ញត្តិនីតិវិធីគ្រប់គ្រងប្រតិបត្តិការនិងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការរៀបចំអភិវឌ្ឍនិងគ្រប់គ្រងគម្រោងភ.រ.ជ. ជាមួយស្ថាប័នសាមី។

៣- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យរបស់គម្រោងភ.រ.ជ.ដែលមានសង្គតិភាពជាមួយក្របខ័ណ្ឌរួមសម្រាប់គ្រប់គ្រងយន្តការភ.រ.ជ.។

៤- ពិនិត្យនិងអនុម័តសំណើគម្រោងដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ អនុវត្តតាមយន្តការភ.រ.ជ. ដោយផ្អែកលើលក្ខណវិនិច្ឆ័យពាក់ព័ន្ធ។

៥- ពិនិត្យលើការបែងចែកការទទួលបន្ទុកហានិភ័យនៃគម្រោងភ.រ.ជ. រវាងរដ្ឋនិងដៃគូឯកជន ដើម្បីធានាអនុលោមភាពជាមួយនឹងច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីធានាចីរភាពហិរញ្ញវត្ថុសាធារណៈ។

៦- ពិនិត្យនិងផ្តល់យោបល់លើកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងការគាំទ្រពីរដ្ឋសម្រាប់គម្រោងភ.រ.ជ.។

៧- ពិនិត្យនិងផ្តល់យោបល់លើកិច្ចសន្យាភ.រ.ជ. និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការអនុវត្តគម្រោងភ.រ.ជ.។

៨- សហការជាមួយស្ថាប័នសាមីនិងស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យនិងតាមដានកាតព្វកិច្ចនិងសមិទ្ធកម្មនៃការអនុវត្តគម្រោង ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៩- ពិនិត្យនិងអនុម័តលើសំណើរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ស្ថាប័នសាមីពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈនិងការគាំទ្រពីរដ្ឋដែលរាជរដ្ឋាភិបាលបានសន្យាបំពេញក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ.។

១០- រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីបច្ចុប្បន្នភាពនៃកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈដែលរាជរដ្ឋាភិបាលបានសន្យាបំពេញក្នុងកិច្ចសន្យាភ.រ.ជ.។

១១- រៀបចំថវិកា គ្រប់គ្រង និងប្រតិបត្តិការ សម្រាប់មូលនិធិអភិវឌ្ឍន៍គម្រោង។

១២- រៀបចំថវិកា គ្រប់គ្រង និងប្រតិបត្តិការ សម្រាប់មូលនិធិបំពេញផលហិរញ្ញវត្ថុ។

មាត្រា៥ .-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវមានអគ្គនាយកដ្ឋានមួយជាសេនាធិការក្នុងការដឹកនាំនិងគ្រប់គ្រងយន្តការភ.រ.ជ. នៅព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋាននេះត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ស្ថាប័នសាមីជាស្ថាប័នមានសមត្ថកិច្ចក្នុងការអភិវឌ្ឍគម្រោងនិង/ឬការបំពេញតួនាទីជាភាគីចុះកិច្ចសន្យាភ.រ.ជ. ជាមួយនឹងដៃគូឯកជន ដែលមានតួនាទីនិងភារកិច្ចជាអាទិ៍៖

១- ធ្វើអត្តសញ្ញាណកម្មនិងអាទិភាវូបនីយកម្មគម្រោងនៅក្នុងវិស័យឬដែនសមត្ថកិច្ចរបស់ខ្លួន និងរៀបចំសំណើសុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យជ្រើសរើសនិងសម្រេចកំណត់សំណើគម្រោងនោះ ជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចបានកំណត់នៅក្នុងមាត្រា៨នៃច្បាប់នេះ។

២- ជ្រើសរើសនិងគ្រប់គ្រងទីប្រឹក្សាគាំទ្រដល់ការរៀបចំអភិវឌ្ឍនិងការអនុវត្តគម្រោងភ.រ.ជ.។

៣- អនុវត្តឬត្រួតពិនិត្យលើការអនុវត្តការសិក្សាសមិទ្ធិលទ្ធភាពបឋមនិងពេញលេញ រួចពិនិត្យនិងផ្តល់ការឯកភាពទៅលើរបាយការណ៍លទ្ធផលនៃការសិក្សានោះ។

៤- លើកសំណើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យលើលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាព មុននឹងបន្តនីតិវិធីជាធរមាន។

៥- ដឹកនាំក្រុមការងាររបស់រាជរដ្ឋាភិបាលអនុវត្តកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជន ដែលនឹងត្រូវអនុវត្តកិច្ចសន្យាភ.រ.ជ.។

៦- ដឹកនាំក្រុមការងាររបស់រាជរដ្ឋាភិបាលចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. និងចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ. ក្នុងនាមជាតំណាងរបស់រាជរដ្ឋាភិបាល។

៧- គ្រប់គ្រងនិងអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងកិច្ចសន្យាភ.រ.ជ.។

៨- លើកសំណើរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈនិងការគាំទ្រពីរដ្ឋដែលរាជរដ្ឋាភិបាលបានសន្យាបំពេញ ក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ.។

៩- តាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តនិងប្រតិបត្តិការគម្រោងភ.រ.ជ. ទាំងមូល។

ស្ថាប័នសាមីត្រូវអនុវត្តតួនាទីនិងភារកិច្ចដូចមានចែងក្នុងកថាខណ្ឌ១ខាងលើ ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

១- ត្រូវអនុវត្តសិទ្ធិនិងបំពេញភារកិច្ច ក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ. ប្រកបដោយសុចរិតភាពនិងដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ.។

២- ត្រូវទទួលខុសត្រូវដោយផ្ទាល់លើការស្នើសុំថវិកាសម្រាប់ចំណាយលើការរៀបចំការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យគម្រោងភ.រ.ជ.។

ជំពូកទី៣

សិទ្ធិចុះកិច្ចសន្យានិងលក្ខណសម្បត្តិគ្រប់គ្រាន់នៃគម្រោង ភ.រ.ជ.

មាត្រា ៦.-

ស្ថាប័នសាធារណៈដែលមានសិទ្ធិចុះកិច្ចសន្យាភ.រ.ជ.ក្នុងនាមជាស្ថាប័នសាមី រួមមានស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាស

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

សាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ស្ថាប័នសាធារណៈទាំងនេះមានសិទ្ធិចុះកិច្ចសន្យាភ.រ.ជ. ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលដែលមានសិទ្ធិទទួលការជ្រើសរើសនិងចុះកិច្ចសន្យាភ.រ.ជ.ក្នុងនាមជាដៃគូឯកជន ដោយអនុលោមតាមជំពូកទី៦នៃច្បាប់នេះត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្រុមហ៊ុនដែលបានចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២- ក្រុមហ៊ុនពាណិជ្ជកម្មបរទេសដែលបានចុះបញ្ជីស្របតាមច្បាប់បរទេស។

៣- សហគ្រាសសាធារណៈដែលមិនមែនជាស្ថាប័នសាមី និងដែលទទួលបានប្រតិភូកម្មអំណាច ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

បុគ្គលដូចមានចែងក្នុងចំណុច២ ក្នុងកថាខណ្ឌ២ខាងលើ ដែលបានចុះកិច្ចសន្យាភ.រ.ជ. និងដែលមិនមានកាតព្វកិច្ចបង្កើតក្រុមហ៊ុនមានគោលបំណងពិសេសដូចមានចែងក្នុងមាត្រា២២ នៃច្បាប់នេះ ត្រូវមកចុះបញ្ជីស្របតាមច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៨ .-

វិស័យមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលពាក់ព័ន្ធនឹងការសាងសង់និង/ឬការផ្គត់ផ្គង់សេវាសម្រាប់គម្រោងភ.រ.ជ.រួមមាន៖

- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈបម្រើដល់វិស័យដឹកជញ្ជូននិងវិស័យភស្តុភារកម្ម មានជាអាទិ៍ផ្លូវថ្នល់ ស្ពាន ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ចំណតសាធារណៈ និងព្រែកជីក
- ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល
- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី បំពង់បង្ហូរប្រេងនិងឧស្ម័ន និងសេវាសាធារណៈផ្សេងទៀត ក្នុងវិស័យរ៉ែនិងថាមពល
- ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក ប្រព័ន្ធបូមស្តារ ប្រព្រឹត្តិកម្មទឹកកខ្វក់ ការគ្រប់គ្រងសំណល់ និងសេវាសាធារណៈផ្សេងទៀតបម្រើឱ្យកិច្ចគាំពារបរិស្ថាន
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យសុខាភិបាល វិស័យអប់រំ វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យទេសចរណ៍ វិស័យវប្បធម៌និងសិល្បៈ វិស័យកីឡា និងលំនៅឋានសង្គម
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានជាអាទិ៍តំបន់សេដ្ឋកិច្ចពិសេស សួនបណ្តុំឧស្សាហកម្មធុនតូចនិងមធ្យម និងសួនបច្ចេកវិទ្យានិងនវានុវត្តន៍
- ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងសេវាមន្ទីរពិសោធន៍ ការគាំទ្រការកែច្នៃ ការរក្សាផលិតផល និងការជំរុញពាណិជ្ជកម្ម
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈពាក់ព័ន្ធនឹងវិស័យកសិកម្មនិងប្រព័ន្ធធារាសាស្ត្រ
- ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈផ្សេងទៀតដែលច្បាប់ដោយឡែកអនុញ្ញាត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

មាត្រា៩ .-

ការធ្វើអត្តសញ្ញាណកម្មនិងការជ្រើសរើសគម្រោងភ.រ.ជ. ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ត្រូវបំពេញតាមលក្ខណវិនិច្ឆ័យទាំងអស់ដូចខាងក្រោម៖

១- ការរៀបចំនិងអនុវត្តគម្រោងនោះ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវនិងក្នុងដែនសមត្ថកិច្ចរបស់ស្ថាប័នសាមី។

២- គម្រោងនោះត្រូវមានគោលដៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិង/ឬការផ្តល់សេវាសាធារណៈ នៅក្នុងវិស័យដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។

៣- គម្រោងនោះត្រូវមានលទ្ធភាពបែងចែកការទទួលបន្ទុកហានិភ័យនៃគម្រោងរវាងរដ្ឋនិងដៃគូឯកជន ដើម្បីឱ្យមានផលចំណេញតាមគោលការណ៍តម្លៃនៃលុយ។

៤- គម្រោងនោះត្រូវមានសក្តានុពលក្នុងការទាក់ទាញធនធានពីវិស័យឯកជន ដើម្បីឱ្យមានមូលដ្ឋានក្នុងការធ្វើវិចារណកម្មចំណាយធនធានសាធារណៈសម្រាប់ការរៀបចំអភិវឌ្ឍគម្រោង។

៥- គម្រោងនោះត្រូវមានរយៈពេលប្រតិបត្តិការយ៉ាងតិច៥(ប្រាំ)ឆ្នាំ និងអាចផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់ប្រកបដោយស្ថិរភាពនិងចីរភាព ក្នុងអាយុកាលទាំងស្រុងនៃគម្រោងក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ.។

គោលការណ៍ណែនាំនៃការធ្វើអត្តសញ្ញាណកម្មនិងការជ្រើសរើសគម្រោងភ.រ.ជ. ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

ជំពូកទី៤
វដ្តនៃគម្រោងភ.រ.ជ.

មាត្រា១០ .-

វដ្តនៃគម្រោងភ.រ.ជ.ផ្តួចផ្តើមដោយរដ្ឋ ត្រូវបានកំណត់ដូចខាងក្រោម៖

១- **ការធ្វើអត្តសញ្ញាណកម្មគម្រោង** : ស្ថាប័នសាមីត្រូវធ្វើអត្តសញ្ញាណកម្មគម្រោងដែលមានសក្តានុពលក្នុងការរៀបចំអភិវឌ្ឍនិងអនុវត្តតាមយន្តការភ.រ.ជ.។

២- **ការជ្រើសរើសគម្រោង** : ស្ថាប័នសាមីដែលមានបំណងរៀបចំអភិវឌ្ឍនិងអនុវត្តគម្រោងតាមយន្តការភ.រ.ជ. ត្រូវវាយតម្លៃសក្តានុភាពនិងអាទិភាពនៃគម្រោងនោះ មុននឹងរៀបចំសំណើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ ជ្រើសរើស និងសម្រេចកំណត់សំណើគម្រោង ជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់និងដាក់បញ្ចូលសំណើគម្រោងនោះទៅក្នុងបញ្ជីគម្រោងអាទិភាពក្នុងក្របខ័ណ្ឌ

គម្រោង ភ.រ.ជ.។ ការវាយតម្លៃគម្រោងដោយស្ថាប័នសាមីនិងការជ្រើសរើសសំណើគម្រោងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្អែកទៅលើលក្ខណវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា៩នៃច្បាប់នេះ។

៣- **ការរៀបចំអភិវឌ្ឍគម្រោង** : ស្ថាប័នសាមីដែលមានសមត្ថកិច្ចក្នុងវិស័យពាក់ព័ន្ធនឹងគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវចាត់ចែងឱ្យមានការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងនោះ។

៤- **ការអនុម័តគម្រោង** : ប្រសិនបើស្ថាប័នសាមីឯកភាពតាមលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោង ស្ថាប័នសាមីត្រូវលើកសំណើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យមុននឹងបន្តនីតិវិធីជាធរមាន។

៥- **កិច្ចលទ្ធកម្ម** : បន្ទាប់ពីការអនុម័តលើគម្រោង ស្ថាប័នសាមីត្រូវអនុវត្តកិច្ចលទ្ធកម្ម ដូចមានចែងក្នុងជំពូកទី៦នៃច្បាប់នេះ ដើម្បីជ្រើសរើសបេក្ខភាពដៃគូឯកជនក្នុងការអនុវត្តគម្រោងភ.រ.ជ.។

៦- **ការចរចាលើកិច្ចសន្យាភ.រ.ជ.** : បន្ទាប់ពីការជ្រើសរើសបេក្ខភាពដៃគូឯកជនរួចហើយ ស្ថាប័នសាមីត្រូវដឹកនាំក្រុមការងាររបស់រាជរដ្ឋាភិបាល ក្នុងការចរចាលើខនិងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.។

៧- **ការអនុម័តលើសេចក្តីព្រាងចុងក្រោយនៃកិច្ចសន្យាភ.រ.ជ.** : បន្ទាប់ពីការចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ត្រូវបានបញ្ចប់ ស្ថាប័នសាមីត្រូវស្នើសុំការសម្រេចអនុម័តពីរាជរដ្ឋាភិបាលលើសេចក្តីព្រាងចុងក្រោយនៃកិច្ចសន្យាភ.រ.ជ. បន្ទាប់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឯកភាពជាគោលការណ៍ដូចមានចែងក្នុងចំណុច២ កថាខណ្ឌ១ ក្នុងមាត្រា២១នៃច្បាប់នេះ។

៨- **ការចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ.** : ស្ថាប័នសាមីដែលទទួលបានប្រតិភូកម្មអំណាចស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងនាមជាភាគីរដ្ឋនិងដៃគូឯកជនត្រូវចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ. ដោយមានការចុះហត្ថលេខារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៩- **ការអនុវត្តនិងគ្រប់គ្រងកិច្ចសន្យាភ.រ.ជ.** :

ក- ដៃគូឯកជនត្រូវទទួលខុសត្រូវជាចម្បង ចំពោះការរៀបចំហិរញ្ញប្បទាន ការរចនាប្លង់វិស្វកម្មលម្អិតការអនុវត្តកិច្ចលទ្ធកម្មជ្រើសរើសអ្នកម៉ៅការ ការងារសាងសង់ ការងារប្រតិបត្តិការនិង/ឬការងារថែទាំ ដោយស្របតាមខនិងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. និងអនុលោមតាមបទប្បញ្ញត្តិក្នុងជំពូកទី៩នៃច្បាប់នេះ។

ខ- ស្ថាប័នសាមីត្រូវគ្រប់គ្រង តាមដាន និងរៀបចំរបាយការណ៍អំពីការអនុវត្តកិច្ចសន្យាភ.រ.ជ. ដែលខ្លួនបានចុះហត្ថលេខា ដោយអនុលោមតាមមាត្រា៤០នៃច្បាប់នេះ។

នីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភ.រ.ជ. ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL

[illegible] .–

ស្ថាប័នសាមីអាចប្រើប្រាស់សេវាទីប្រឹក្សាដើម្បីគាំទ្រការងាររៀបចំអភិវឌ្ឍនិង/ឬវាយតម្លៃគម្រោង កិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជននិងការងារពាក់ព័ន្ធផ្សេងទៀត។ ការទូទាត់ថ្លៃសេវាកម្មរបស់

ទីប្រឹក្សាអាចប្រើប្រាស់ថវិកាថ្នាក់ជាតិ ថវិកាថ្នាក់ក្រោមជាតិ ថវិកាគ្រឹះស្ថានសាធារណៈរដ្ឋបាល ថវិកាសហគ្រាសសាធារណៈ មូលនិធិអភិវឌ្ឍន៍គម្រោង ជំនួយផ្សេងៗរបស់ដៃគូអភិវឌ្ឍនិង/ឬប្រភពថវិកាស្របច្បាប់ផ្សេងទៀត។

នីតិវិធីនៃការជ្រើសរើសទីប្រឹក្សា ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

ជំពូកទី៥
យន្តការគាំទ្រផ្នែកហិរញ្ញវត្ថុ

មាត្រា១២ .-

ត្រូវបានបង្កើតមូលនិធិអភិវឌ្ឍន៍គម្រោង ដើម្បីផ្តល់ថវិកាដល់ស្ថាប័នសាមីសម្រាប់ចំណាយលើទីប្រឹក្សាដែលគាំទ្រការងាររៀបចំអភិវឌ្ឍនិង/ឬវាយតម្លៃគម្រោង អនុវត្តកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជននិងការងារពាក់ព័ន្ធផ្សេងទៀត។

គោលការណ៍ណែនាំនៃការគ្រប់គ្រងប្រតិបត្តិការមូលនិធិអភិវឌ្ឍន៍គម្រោង ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

មាត្រា១៣ .-

ការផ្តល់ការគាំទ្រពីរដ្ឋសម្រាប់គម្រោងភ.រ.ឯ. អាចមានទម្រង់ដូចខាងក្រោម៖

១- **ការបំពេញផលហិរញ្ញវត្ថុ** : ជាការឧបត្ថម្ភធនពីរដ្ឋជូនចំពោះដៃគូឯកជន ដើម្បីបន្ថយចំណាយមូលធនរបស់ដៃគូឯកជននិងបង្កើនផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោង។ ការទូទាត់ប្រាក់ឧបត្ថម្ភធនបែបនេះ ត្រូវអនុវត្តតាមការសម្រេចបង្គោលចរសមិទ្ធផលការងារ នៅក្រោយពេលការងារសាងសង់បានចាប់ផ្តើមនិងអាចបន្តយូរបំផុតត្រឹម២(ពីរ)ឆ្នាំ ក្រោយពេលការងារសាងសង់បានបញ្ចប់ជាស្ថាពរ។ គោលការណ៍លម្អិតនៃការបំពេញផលហិរញ្ញវត្ថុត្រូវអនុវត្តតាមនីតិវិធីនៃការគ្រប់គ្រងមូលនិធិបំពេញផលហិរញ្ញវត្ថុ។

២- **ការទូទាត់ថ្លៃសេវាផ្អែកលើថវិការដ្ឋ** : ជាការទូទាត់ទាំងស្រុងឬមួយចំណែកនៃថ្លៃសេវារបស់ដៃគូឯកជនសម្រាប់ការងារធ្វើប្រតិបត្តិការលើទ្រព្យសម្បត្តិគម្រោងភ.រ.ឯ.និង/ឬការផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់សាធារណៈ។ ការទូទាត់ថ្លៃសេវាផ្អែកលើថវិការដ្ឋអាចអនុវត្តបានក្នុងករណីរាជរដ្ឋាភិបាលឯកភាពថាកម្រៃសេវាដែលដៃគូឯកជនត្រូវប្រមូលពីអ្នកប្រើប្រាស់សាធារណៈ មិនគ្រប់គ្រាន់ ឬមិនអាចប្រមូលបាន ឬមិនគួរប្រមូលពីអ្នកប្រើប្រាស់សាធារណៈ។ ការទូទាត់បែបនេះត្រូវអនុវត្តនៅក្រោយពេលការងារសាងសង់ត្រូវបានបញ្ចប់ជាស្ថាពរក្នុងករណីមានការសាងសង់ និងនៅពេលប្រតិបត្តិការការងារគម្រោងត្រូវបានចាប់ផ្តើម។

៣- **កាតព្វកិច្ចបំណុលជាយថាហេតុរបស់រដ្ឋ** : ជាកិច្ចធានាមួយចំនួនដែលផ្តល់ជូនដៃគូឯកជនប្រាក់ពាក់ព័ន្ធក្នុងករណីពិសេសដើម្បីដោះស្រាយផលប៉ះពាល់ដែលអាចនឹងកើតឡើងដោយសារ

ព្រឹត្តិការណ៍ជាយថាហេតុនិង/ឬហានិភ័យដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ការសម្រេចផ្តល់កិច្ចធានាត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ អាស្រ័យលើលក្ខណៈនៃគម្រោងភ.រ.ជ.នីមួយៗ រាជរដ្ឋាភិបាលអាចផ្តល់កិច្ចធានាដែលមានទម្រង់ដូចខាងក្រោម៖

ក- **កិច្ចធានាសមិទ្ធកម្មតាមកិច្ចសន្យា** : ជាកិច្ចធានាដែលផ្តល់សំណងក្នុងករណីស្ថាប័នសាមីឬស្ថាប័នសាធារណៈណាមួយមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. ឬកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការអនុវត្តគម្រោងភ.រ.ជ.។

ខ- **កិច្ចធានាចំពោះហានិភ័យអធិបតេយ្យឬនយោបាយ** : ជាកិច្ចធានាដែលផ្តល់សំណងក្នុងករណីសកម្មភាពនយោបាយឬគោលនយោបាយរបស់រាជរដ្ឋាភិបាល ធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានចំពោះដៃគូឯកជន មានជាអាទិ៍ករណីអស្សាមិករណ៍ ករណីជាតូបនីយកម្ម និងករណីអំពើហិង្សាដែលកើតឡើងដោយសារសកម្មភាពនយោបាយ។

គ- **កិច្ចធានាផ្សេងទៀត** : ជាកិច្ចធានាទម្រង់ផ្សេងទៀតដែលអនុម័តដោយរាជរដ្ឋាភិបាល អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៤- **វិភាគទានជាទ្រព្យសម្បត្តិ** : ជាការផ្តល់វិភាគទានដែលជាទ្រព្យសម្បត្តិរដ្ឋចំពោះគម្រោងភ.រ.ជ.។

៥- **ការលើកទឹកចិត្តវិនិយោគ** : ជាការផ្តល់ការលើកទឹកចិត្តវិនិយោគនិង/ឬការរៀបចំគោលនយោបាយអនុគ្រោះចំពោះការវិនិយោគ ដោយអនុលោមតាមជំពូកទី៨នៃច្បាប់នេះ។

មាត្រា១៤ .–

ការគាំទ្រពីរដ្ឋសម្រាប់គម្រោងភ.រ.ជ.ដែលមានលក្ខណៈជាថវិកាអាចមានប្រភពហិរញ្ញប្បទានដូចខាងក្រោម៖

១- ថវិកាថ្នាក់ជាតិ ថវិកាថ្នាក់ក្រោមជាតិ ថវិការបស់អង្គភាពសាធារណៈប្រហាក់ប្រហែលថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិង/ឬថវិការបស់សហគ្រាសសាធារណៈ។

២- ជំនួយអភិវឌ្ឍន៍ផ្លូវការ ដូចជាប្រាក់កម្ចីឬជំនួយឥតសំណង ដែលរាជរដ្ឋាភិបាលទទួលបានពីដៃគូអភិវឌ្ឍ។

៣- មូលនិធិបំពេញផលហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា១៥នៃច្បាប់នេះ។

មាត្រា១៥ .–

ត្រូវបានបង្កើតមូលនិធិបំពេញផលហិរញ្ញវត្ថុដែលជាប្រភពហិរញ្ញប្បទានពិសេសមួយសម្រាប់ផ្តល់ការបំពេញផលហិរញ្ញវត្ថុដល់គម្រោងភ.រ.ជ.។

នីតិវិធីនៃការគ្រប់គ្រងមូលនិធិបំពេញផលហិរញ្ញវត្ថុ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

មាត្រា១៦ .-

គម្រោងភ.រ.ជ.ណាដែលទទួលបានការគាំទ្រពីរដ្ឋជាថវិកាឬត្រូវផ្ទេរប្រាក់ជូនរដ្ឋត្រូវធ្វើប្រតិបត្តិការទាំងនេះ តាមរយៈគណនីនៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ កិច្ចសន្យាភ.រ.ជ.អាចតម្រូវឱ្យមានគណនីនៅធនាគារបន្ថែមទៀត តាមតម្រូវការចាំបាច់។

ជំពូកទី៦
ការជ្រើសរើសដៃគូឯកជន

មាត្រា១៧ .-

ការជ្រើសរើសដៃគូឯកជនអាចធ្វើឡើងសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋនិងសម្រាប់គម្រោងផ្តួចផ្តើមដោយឯកជន។

មាត្រា១៨ .-

ការជ្រើសរើសដៃគូឯកជនសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋអាចអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងឬតាមវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់។

នីតិវិធីនៃការជ្រើសរើសដៃគូឯកជនសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

មាត្រា១៩ .-

ដំណើរការនៃការចរចាលើកិច្ចសន្យាភ.រ.ជ.សម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋដែលអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែង ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកដេញថ្លៃជាប់លំដាប់លេខរៀងទី១ ត្រូវបានអញ្ជើញមកចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាលដែលដឹកនាំដោយស្ថាប័នសាមី ដូចមានចែងក្នុងចំណុច៦នៃកថាខណ្ឌ១ ក្នុងមាត្រា១០នៃច្បាប់នេះ។ ក្នុងករណីដែលអ្នកដេញថ្លៃជាប់លំដាប់លេខរៀងទី១នោះខកខានក្នុងការចូលរួមការចរចាតាមការអញ្ជើញ ស្ថាប័នសាមីអាចអញ្ជើញអ្នកដេញថ្លៃជាប់លំដាប់លេខរៀងបន្ទាប់ មកចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.។

២- ក្នុងករណីដែលការចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ដូចមានចែងក្នុងចំណុច១នៃកថាខណ្ឌ១ខាងលើ មិនបានបញ្ចប់ក្នុងរយៈពេល៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញឱ្យចូលចរចាដំបូង នោះស្ថាប័នសាមីអាចអញ្ជើញអ្នកដេញថ្លៃជាប់លំដាប់លេខរៀងបន្ទាប់មកចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.។

៣- ឯកសារប្រកាសការអញ្ជើញដាក់សំណើសុំចូលរួមដេញថ្លៃអាចបញ្ជាក់ជាមុននូវខ និងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ដែលមិនអាចចរចាបាន។

គោលការណ៍លម្អិតសម្រាប់ការចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងសម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋ ត្រូវកំណត់ក្នុងនីតិវិធីនៃការជ្រើសរើសដៃគូឯកជន។

មាត្រា២០ .-

ស្ថាប័នសាមីអាចអនុវត្តវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់សម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋក្នុងករណីមានការសម្រេចពីរាជរដ្ឋាភិបាល តាមសំណើរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នសាមី។

គោលការណ៍លម្អិតសម្រាប់ការចរចាលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. តាមវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់ ត្រូវកំណត់នៅក្នុងនីតិវិធីនៃការជ្រើសរើសដៃគូឯកជន។

មាត្រា២១ .-

ដំណើរការនៃការបញ្ចប់ការរៀបចំនិងចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ.សម្រាប់គម្រោងផ្តួចផ្តើមដោយរដ្ឋ ត្រូវបានកំណត់ដូចខាងក្រោម៖

១- បន្ទាប់ពីការចរចាលើខនិងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ត្រូវបានបញ្ចប់ ស្ថាប័នសាមីត្រូវរៀបចំសំណើសុំការអនុម័តលើសេចក្តីព្រាងចុងក្រោយនៃកិច្ចសន្យាភ.រ.ជ. ដូចមានចែងក្នុងចំណុច៧ នៃកថាខណ្ឌ១ ក្នុងមាត្រា១០នៃច្បាប់នេះ។

២- មុននឹងស្នើសុំការអនុម័តដូចមានចែងក្នុងចំណុច១ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិនិត្យឡើងវិញលើខនិងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ដែលពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈនិងការគាំទ្រពីរដ្ឋ រួចបន្តនីតិវិធីតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ខនិងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងការគាំទ្រពីរដ្ឋក្នុងកិច្ចសន្យាភ.រ.ជ.មានជាអាទិ៍៖

ក- ប្រភេទហានិភ័យនិងការបែងចែកការទទួលបន្ទុកហានិភ័យរវាងភាគីរដ្ឋនិងដៃគូឯកជន។

ខ- ការគាំទ្រពីរដ្ឋដូចមានចែងក្នុងមាត្រា១៣នៃច្បាប់នេះ។

គ- កាតព្វកិច្ចរបស់រដ្ឋដូចមានចែងក្នុងមាត្រា៣៤នៃច្បាប់នេះ។

៣- បន្ទាប់ពីការអនុម័តលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.ដូចមានចែងក្នុងចំណុច១និង២ នៃកថាខណ្ឌ១ខាងលើ កិច្ចសន្យានោះត្រូវមានការចុះហត្ថលេខាដោយស្ថាប័នសាមីនិងដៃគូឯកជន ក្រោមការចុះហត្ថលេខារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គោលការណ៍លម្អិតនៃការបញ្ចប់ការរៀបចំនិងអនុម័តលើសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ត្រូវកំណត់នៅក្នុងនីតិវិធីនៃការជ្រើសរើសដៃគូឯកជន។

មាត្រា២២ .-

ក្រុមហ៊ុនមានគោលបំណងពិសេសអាចត្រូវបង្កើតឡើង ដើម្បីធ្វើជាដៃគូឯកជនក្នុងកិច្ចសន្យា ភ.រ.ជ. តាមតម្រូវការជាក់ស្តែងរបស់គម្រោងនីមួយៗ។

ការបង្កើតក្រុមហ៊ុនមានគោលបំណងពិសេស ដើម្បីធ្វើជាដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ជ. ត្រូវអនុលោមតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ក្រុមហ៊ុនមានគោលបំណងពិសេសត្រូវបង្កើតឡើងជាសហគ្រាសពាណិជ្ជកម្ម ដោយចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២- ការបង្កើតនិងការចុះបញ្ជីក្រុមហ៊ុនមានគោលបំណងពិសេសត្រូវបញ្ចប់យ៉ាងយូរបំផុតត្រឹម៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាភ.រ.ជ.។

៣- ក្នុងរយៈពេល១៤(ដប់បួន)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការបង្កើត និងការចុះបញ្ជីក្រុមហ៊ុនមានគោលបំណងពិសេស ភាគីនៃកិច្ចសន្យាភ.រ.ជ.និងក្រុមហ៊ុនមានគោលបំណងពិសេសត្រូវចុះកិច្ចព្រមព្រៀងនវកម្ម ដើម្បីធ្វើអនុប្បទានឋានៈរបស់ដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ជ. ជូនក្រុមហ៊ុនមានគោលបំណងពិសេស ដោយរក្សាខនិងលក្ខខណ្ឌនៃកិច្ចសន្យា ភ.រ.ជ. ដដែល។

មាត្រា២៣ .-

ស្ថាប័នសាមីអាចទទួលសំណើគម្រោងផ្តួចផ្តើមដោយឯកជន ដើម្បីពិនិត្យលទ្ធភាពរៀបចំអភិវឌ្ឍ និងអនុវត្តជាគម្រោងភ.រ.ជ.។ ការពិនិត្យនិងសម្រេចលើសំណើគម្រោងផ្តួចផ្តើមដោយឯកជនត្រូវអនុលោមតាមគោលការណ៍និងលក្ខខណ្ឌដូចខាងក្រោម៖

១- សំណើគម្រោងផ្តួចផ្តើមដោយឯកជនត្រូវមានទស្សនាទានថ្មី បច្ចេកវិទ្យាថ្មី ឬនវានុវត្តន៍ដែលអាចមានប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីស្ថាប័នសាមីមានបំណងបន្តការរៀបចំអភិវឌ្ឍសំណើគម្រោងផ្តួចផ្តើមដោយឯកជនណាមួយ ស្ថាប័នសាមីត្រូវរៀបចំសំណើសុំការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- បន្ទាប់ពីទទួលបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល ស្ថាប័នសាមីត្រូវដឹកនាំក្រុមការងាររបស់រាជរដ្ឋាភិបាលរៀបចំកិច្ចព្រមព្រៀងក្របខ័ណ្ឌ ឬកិច្ចព្រមព្រៀងណាមួយ ដើម្បីកំណត់ពីកិច្ចសហប្រតិបត្តិការរវាងភាគីរដ្ឋនិងម្ចាស់សំណើគម្រោងផ្តួចផ្តើមដោយឯកជន ក្នុងការសិក្សានិងអភិវឌ្ឍគម្រោង។ រាល់ចំណាយនិងហានិភ័យពាក់ព័ន្ធនឹងការសិក្សានិងអភិវឌ្ឍគម្រោង គឺជាបន្ទុករបស់សំណើគម្រោងផ្តួចផ្តើមដោយឯកជន។

៣- ស្ថាប័នសាមីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចាត់ចែងឱ្យមានភ្នាក់ងារឯករាជ្យ

ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញឬធ្វើការវាយតម្លៃលើលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពរបស់ម្ចាស់សំណើគម្រោងផ្តួចផ្តើមដោយឯកជន។

៤- ផ្អែកលើការវាយតម្លៃនៃការសិក្សាសមិទ្ធិលទ្ធភាព ស្ថាប័នសាមីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចស្នើសុំរាជរដ្ឋាភិបាលជ្រើសរើសដៃគូឯកជន តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែង ឬតាមវិធីសាស្ត្រការចុះកិច្ចសន្យាផ្ទាល់។

៥- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចសម្រេចប្រើប្រាស់ថវិកាពីមូលនិធិអភិវឌ្ឍន៍គម្រោងសម្រាប់ការវាយតម្លៃភាពត្រឹមត្រូវនៃការសិក្សាសមិទ្ធិលទ្ធភាពនេះ លើទិដ្ឋភាពពាណិជ្ជកម្ម និងហិរញ្ញវត្ថុ សម្រាប់ការចរចាលើខនិងលក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. និងសម្រាប់ការងារពាក់ព័ន្ធផ្សេងទៀត។

នីតិវិធីនៃការជ្រើសរើសដៃគូឯកជនសម្រាប់គម្រោងផ្តួចផ្តើមដោយឯកជន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

ជំពូកទី៧
កិច្ចសន្យាភ.រ.ជ.

មាត្រា២៤ .-

គោលការណ៍កិច្ចសន្យាភ.រ.ជ. ត្រូវបានកំណត់ដូចខាងក្រោម៖

១- កិច្ចសន្យាភ.រ.ជ. ត្រូវរៀបចំឡើងដោយផ្អែកទៅលើលក្ខណៈពិសេសនៃគម្រោង ដូចមានកំណត់នៅក្នុងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាព ដែលនឹងត្រូវមានការឯកភាពរវាងរាជរដ្ឋាភិបាលនិងដៃគូឯកជន។

២- កិច្ចសន្យាភ.រ.ជ. ត្រូវតែជាកិច្ចព្រមព្រៀងបែបពាណិជ្ជកម្មរវាងស្ថាប័នសាមីនិងដៃគូឯកជន។ ស្ថាប័នសាមីត្រូវទទួលខុសត្រូវក្នុងការធានាថា ការចុះកិច្ចសន្យាភ.រ.ជ. ប្រព្រឹត្តទៅប្រកបដោយតម្លាភាពនិងភាពយុត្តិធម៌សម្រាប់គម្រោងភ.រ.ជ.ទាំងអស់ ទាំងគម្រោងផ្តួចផ្តើមដោយរដ្ឋ និងទាំងគម្រោងផ្តួចផ្តើមដោយឯកជន។

៣- កិច្ចសន្យាភ.រ.ជ. ត្រូវបែងចែកការទទួលបន្ទុកហានិភ័យពាក់ព័ន្ធនឹងគម្រោងភ.រ.ជ. រវាងរាជរដ្ឋាភិបាលនិងដៃគូឯកជន ដោយធ្វើឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពទទួលផលចំណេញតាមគោលការណ៍តម្លៃនៃលុយ ប៉ុន្តែនៅតែមានលទ្ធភាពរក្សាផលចំណេញពីពាណិជ្ជកម្មក្នុងកម្រិតសមរម្យឱ្យដៃគូឯកជន។

៤- ការកំណត់ផលប្រយោជន៍ដែលដៃគូឯកជនមានសិទ្ធិទទួលបានក្នុងកិច្ចសន្យាភ.រ.ជ. ត្រូវផ្អែកទៅលើសមិទ្ធកម្មនៃការអនុវត្តគម្រោង។

មាត្រា២៥ .-

សេចក្តីព្រាងកិច្ចសន្យាភ.រ.ជ.នីមួយៗត្រូវមានទម្រង់ផ្អែកទៅលើប្រភេទគម្រោងភ.រ.ជ.ដែលសមស្របណាមួយ។ ការកំណត់ប្រភេទគម្រោងភ.រ.ជ.សមស្រប អាស្រ័យទៅលើលក្ខណៈពិសេសនិងតម្រូវការជាក់ស្តែងរបស់គម្រោងនីមួយៗនិងត្រូវមានការសម្រេចដោយស្ថាប័នសាមីជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកទៅលើលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាព។

ប្រភេទគម្រោងភ.រ.ជ.ដែលមានការប្រើប្រាស់ជាទូទៅក្នុងការរៀបចំសេចក្តីព្រាងកិច្ចសន្យាភ.រ.ជ. ត្រូវបានកំណត់ជាអាទិ៍ ដូចក្នុងឧបសម្ព័ន្ធ២នៃច្បាប់នេះ។

មាត្រា២៦ .-

ថ្លៃប្រើប្រាស់និងកម្រៃសេវាទាំងឡាយដែលអាចប្រមូលបានក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ. ព្រមទាំងរូបមន្តកែប្រែត្រូវមានការកំណត់នៅក្នុងកិច្ចសន្យាភ.រ.ជ.។ ការកំណត់នេះ ត្រូវឈរលើគោលការណ៍ធានាអត្រាផលចំណេញក្នុងកម្រិតសមរម្យចំពោះដៃគូឯកជន ប៉ុន្តែនៅតែអាចធានាតម្លៃសមរម្យចំពោះអ្នកប្រើប្រាស់និងភាគីរដ្ឋ។

ដៃគូឯកជនមានសិទ្ធិប្រមូល និងទទួលចំណូលពីថ្លៃប្រើប្រាស់ និងកម្រៃសេវាផ្សេងៗ និងមានសិទ្ធិធ្វើការកែប្រែថ្លៃប្រើប្រាស់និងកម្រៃសេវាទាំងនោះតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.និង/ឬកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការអនុវត្តគម្រោងភ.រ.ជ.។

មាត្រា២៧ .-

កិច្ចសន្យាភ.រ.ជ.ត្រូវគ្រប់គ្រងដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ដៃគូឯកជនអាចជ្រើសរើសច្បាប់គ្រប់គ្រងលើកិច្ចព្រមព្រៀងបន្ទាប់បន្សំដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាភ.រ.ជ. វៀរលែងតែមានស្ថាប័នសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាជាភាគីនៅក្នុងកិច្ចព្រមព្រៀងនោះ។

មាត្រា២៨ .-

ការធ្វើអនុប្បទានសិទ្ធិនិងកាតព្វកិច្ចណាមួយរបស់ដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ជ.ទៅឱ្យតតិយជន ត្រូវមានការឯកភាពពីរាជរដ្ឋាភិបាលជាមុនសិន វៀរលែងតែករណីសិទ្ធិចូលអន្តរាគមន៍ដូចមានចែងក្នុងមាត្រា២៩នៃច្បាប់នេះ។

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់លក្ខខណ្ឌ រាប់បញ្ចូលទាំងលក្ខខណ្ឌដែលអនុប្បទាយី និង[illegible]ទា[illegible]ត្រូវបំពេញដើម្បីទទួលការឯកភាពពីរាជរដ្ឋាភិបាលលើការធ្វើអនុប្បទានសិទ្ធិនិងកាតព្វកិច្ច[illegible]របស់ដៃគូឯកជននៅក្នុងកិច្ចសន្យាភ.រ.ជ.។

មាត្រា២៩ .–

គូភាគីនៃកិច្ចសន្យាភ.រ.ជ. អាចព្រមព្រៀងគ្នាក្នុងការផ្តល់សិទ្ធិចូលអន្តរាគមន៍ជូនចំពោះអ្នកផ្តល់ប្រាក់កម្ចីសម្រាប់គម្រោងនិង/ឬជូនចំពោះរាជរដ្ឋាភិបាល។ អ្នកទទួលសិទ្ធិចូលអន្តរាគមន៍អាចទទួលនិងអនុវត្តបន្តនូវសិទ្ធិនិងកាតព្វកិច្ច ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. ក្នុងគោលបំណងជានាចីរភាពនៃការបំពេញកាតព្វកិច្ចរបស់ដៃគូឯកជន ក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ.និង/ឬកិច្ចព្រមព្រៀងប្រាក់កម្ចីដែលពាក់ព័ន្ធនឹងគម្រោង។

មាត្រា៣០ .–

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់លក្ខខណ្ឌកែប្រែកិច្ចសន្យា។ លក្ខខណ្ឌដែលអាចធ្វើការកែប្រែកិច្ចសន្យាភ.រ.ជ.ពាក់ព័ន្ធនឹងការងារសាងសង់និង/ឬសេវា មានជាអាទិ៍ការផ្លាស់ប្តូរច្បាប់ឬបទប្បញ្ញត្តិ ការផ្លាស់ប្តូរទំហំឬបទដ្ឋានយថាប្រភេទជាតុចេញនៃការងារសាងសង់ ការកែប្រែថ្លៃប្រើប្រាស់សេវា បម្រែបម្រួលតម្រូវការសេវា ប្រធានសក្តិ ឬលក្ខខណ្ឌផ្សេងទៀត ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ស្ថាប័នសាមីត្រូវស្នើសុំការសម្រេចពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើករណីកែប្រែកិច្ចសន្យាភ.រ.ជ.ដោយអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មុននឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការកែប្រែលើកិច្ចសន្យាភ.រ.ជ. ជាមួយដៃគូឯកជន។

ការកែប្រែកិច្ចសន្យាភ.រ.ជ. ត្រូវអនុវត្តតាមគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងកិច្ចសន្យាដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

ជំពូកទី៨
ការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោង ភ.រ.ជ.

មាត្រា៣១ .–

បុគ្គលទាំងឡាយណាដែលអនុវត្តគម្រោងភ.រ.ជ. ត្រូវស្ថិតនៅក្រោមនីតិរបបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានាស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣២ .–

ដៃគូឯកជនអាចដាក់ពាក្យស្នើសុំការលើកទឹកចិត្តវិនិយោគសម្រាប់គម្រោងភ.រ.ជ.ដោយអនុលោមតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានិងច្បាប់ពាក់ព័ន្ធជាធរមានផ្សេងទៀត។

មាត្រា៣៣ .–

ការបង្កើតសិទ្ធិប្រាតិភោគពាក់ព័ន្ធនឹងទ្រព្យសម្បត្តិគម្រោង ត្រូវអនុលោមតាមលក្ខខណ្ឌដូចខាងក្រោម ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១- ក្នុងរយៈពេលនៃកិច្ចសន្យាភ.រ.ជ. ដៃគូឯកជនអាចបង្កើតសិទ្ធិប្រាតិភោគលើទ្រព្យសម្បត្តិ លើសិទ្ធិឬលើអត្ថប្រយោជន៍របស់ខ្លួនដែលពាក់ព័ន្ធនឹងកិច្ចសន្យាភ.រ.ជ. រួមមានៈ

ក- ប្រាតិភោគលើចលនទ្រព្យឬអចលនទ្រព្យពាក់ព័ន្ធនឹងគម្រោងដែលជាកម្មសិទ្ធិរបស់ដៃគូឯកជន។

ខ- ប្រាតិភោគលើផលនៃទ្រព្យជានាឬគណនីត្រូវទាររបស់ដៃគូឯកជន ដែលបានមកពីការធ្វើប្រតិបត្តិការលើទ្រព្យសម្បត្តិគម្រោងឬការផ្ដល់សេវាកម្មដល់អ្នកប្រើប្រាស់សេវា។

គ- ការដាក់បញ្ចាំនៃសិទ្ធិប្រត្យក្សលើដី ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- វិនិយោគិនអាចបង្កើតសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ខ្លួនក្នុងក្រុមហ៊ុនមានគោលបំណងពិសេស។

៣- ការបង្កើត ការចុះបញ្ជី និងការធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគ ដូចមានចែងក្នុងចំណុច១ និង២នៃកថាខណ្ឌ១ខាងលើ ត្រូវអនុលោមតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. ហើយត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣៤ .-

រាជរដ្ឋាភិបាលអាចបង្កើតកាតព្វកិច្ចនានាចំពោះដៃគូឯកជនឬបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងគម្រោងភ.រ.ជ. រាប់បញ្ចូលទាំងអ្នកផ្ដល់ប្រាក់កម្ចីក្នុងគោលបំណងធ្វើឱ្យគម្រោងនោះមានសមិទ្ធិលទ្ធភាពផ្នែកហិរញ្ញវត្ថុ មានលទ្ធភាពទទួលហិរញ្ញប្បទាន និងមានលទ្ធភាពអនុវត្តការងារសាងសង់ និងប្រតិបត្តិការឱ្យបានទាន់ពេលវេលា។ កាតព្វកិច្ចទាំងនោះមានជាអាទិ៍ៈ

១- កិច្ចធានារបស់រាជរដ្ឋាភិបាលចំពោះដៃគូឯកជន ដូចមានចែងក្នុងចំណុច៣នៃកថាខណ្ឌ១ ក្នុងមាត្រា១៣នៃច្បាប់នេះ។

២- ការចុះកិច្ចព្រមព្រៀងផ្ទាល់រវាងស្ថាប័នសាមីនិងអ្នកផ្ដល់ប្រាក់កម្ចី ដើម្បីបញ្ជាក់ពីកាតព្វកិច្ចរបស់ស្ថាប័នសាមី ដែលមានចែងនៅក្នុងកិច្ចសន្យាភ.រ.ជ.។

៣- ការធានាឱ្យមានសេវាសាធារណៈ ដែលដៃគូឯកជនត្រូវការជាចាំបាច់ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ.។

៤- កាតព្វកិច្ចផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ការអនុម័តនិងការអនុវត្តកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលទាំងឡាយក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ. ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៣៥ .–

កិច្ចលទ្ធកម្មដី ការដោះស្រាយផលប៉ះពាល់ និងការផ្តល់សិទ្ធិពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋសម្រាប់គម្រោងភ.រ.ជ. ជូនដៃគូឯកជន ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់សិទ្ធិប្រត្យក្សលើដី ការបែងចែកការទទួលបន្ទុកចំណាយកិច្ចលទ្ធកម្មដីនិងចំណាយលើសិទ្ធិប្រត្យក្សលើដី ព្រមទាំងចំណាយពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋសម្រាប់គម្រោងភ.រ.ជ.។

មាត្រា៣៦ .–

ដៃគូឯកជនមានសិទ្ធិទិញរូបិយបណ្ណនិងផ្ទេររូបិយបណ្ណទាំងនេះទៅបរទេស តាមរយៈប្រព័ន្ធធនាគារដែលជាអន្តរការីប្រតិស្រុតិ ដើម្បីទូទាត់លើប្រតិបត្តិការពាណិជ្ជកម្ម ប្រតិបត្តិការដើមទុន និងប្រតិបត្តិការផ្សេងទៀត ដែលពាក់ព័ន្ធនឹងការវិនិយោគលើគម្រោងភ.រ.ជ.មានជាអាទិ៍៖

១- ការទូទាត់លើការនាំចូលទំនិញនិងសេវាកម្មពីបរទេស។

២- ការបង់ប្រាក់ដើមនិងការប្រាក់សម្រាប់កម្ចីពីបរទេស។

៣- ការបង់ថ្លៃអាជ្ញាបណ្ណនិងកម្រៃគ្រប់គ្រងជូនអង្គភាពបរទេស។

៤- ការទូទាត់លើការជួលឧបករណ៍និងម៉ាស៊ីនពីបរទេស។

៥- ចំពោះតែវិនិយោគិនបរទេស ការផ្ទេរទៅបរទេសនូវដើមទុន ប្រាក់ចំណេញ ប្រាក់ចំណូលពីការជម្រះបញ្ជីនៃការវិនិយោគនិងប្រាក់ចំណូលស្របច្បាប់ផ្សេងទៀត។

សកម្មភាពប្តូររូបិយបណ្ណរបស់ដៃគូឯកជន ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី៩
ការអនុវត្តនិងការតាមដានគម្រោង

មាត្រា៣៧ .–

ដៃគូឯកជនអាចអនុវត្តកិច្ចសន្យាភ.រ.ជ. ដោយផ្ទាល់ខ្លួនឬតាមរយៈអ្នកម៉ៅការ។

បេក្ខភាពដៃគូឯកជនត្រូវបញ្ជាក់អ្នកម៉ៅការគន្លឹះរបស់ខ្លួនឱ្យបានច្បាស់លាស់នៅក្នុងឯកសារសំណើគម្រោង នៅពេលចូលរួមក្នុងដំណើរការលទ្ធកម្មជ្រើសរើសដៃគូឯកជន។ និយមន័យនៃអ្នកម៉ៅការគន្លឹះ អាស្រ័យលើលក្ខណៈពិសេសនិងវិសាលភាពនៃគម្រោងភ.រ.ជ.នីមួយៗ និងត្រូវកំណត់ក្នុងឯកសារសម្រាប់អនុវត្តកិច្ចលទ្ធកម្ម។ ការផ្លាស់ប្តូរអ្នកម៉ៅការគន្លឹះមិនត្រូវបានអនុញ្ញាតទេ [illegible]តែមានការឯកភាពពីស្ថាប័នសាមីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

ដៃគូឯកជនមានសិទ្ធិពេញលេញក្នុងការជ្រើសរើសនិងផ្លាស់ប្តូរអ្នកម៉ៅការណាដែលមិនមែន

ជាអ្នកម៉ៅការគន្លឹះ ដោយពុំចាំបាច់សុំការឯកភាពពីស្ថាប័នសាមីជាមុនឡើយ។

ទោះបីជាមានឬមិនមានអ្នកម៉ៅការក្តី ដៃគូឯកជនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះសមិទ្ធកម្មនៃការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ.។

មាត្រា៣៨ .-

ប្រសិនបើគម្រោងភ.រ.ជ.ត្រូវការឱ្យដៃគូឯកជនធានាសមិទ្ធកម្មការងារប្រតិបត្តិការនៃគម្រោងនោះ ដៃគូឯកជនត្រូវផ្តល់កិច្ចធានានេះ ជូនចំពោះស្ថាប័នសាមី ដើម្បីធានាថាការអនុវត្តការងារប្រតិបត្តិការដោយដៃគូឯកជននឹងប្រព្រឹត្តទៅបានត្រឹមត្រូវតាមប៉ារ៉ាម៉ែត្រ និងបទដ្ឋានយថាប្រភេទផ្សេងៗ ដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ឯកសារសម្រាប់អនុវត្តកិច្ចលទ្ធកម្មជ្រើសរើសដៃគូឯកជន និងកិច្ចសន្យាភ.រ.ជ. ត្រូវកំណត់នូវតម្រូវការទម្រង់ តម្លៃ និងសុពលភាពនៃកិច្ចធានាសមិទ្ធកម្មការងារប្រតិបត្តិការ ដែលដៃគូឯកជននឹងត្រូវផ្តល់។

មាត្រា៣៩ .-

ការងារគ្រប់គ្រង ធ្វើប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិគម្រោងជាលក្ខណៈពាណិជ្ជកម្មស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមខនិងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ. អាចអនុវត្តដោយដៃគូឯកជនដោយផ្ទាល់ឬតាមរយៈអ្នកម៉ៅការទទួលការងារគ្រប់គ្រងជំនួស។ ក្នុងករណីមានអ្នកម៉ៅការទទួលការងារគ្រប់គ្រងជំនួស ដៃគូឯកជននៅតែត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះសមិទ្ធកម្មនៃការបំពេញកាតព្វកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹងការងារគ្រប់គ្រងធ្វើប្រតិបត្តិការនិងថែទាំទ្រព្យសម្បត្តិគម្រោង ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ក្នុងអំឡុងពេលអនុវត្តការងារគ្រប់គ្រង ធ្វើប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិគម្រោង ដៃគូឯកជនត្រូវបំពេញកាតព្វកិច្ចមានជាអាទិ៍៖

១- អនុវត្តសិទ្ធិធ្វើអាជីវកម្មលើទ្រព្យសម្បត្តិគម្រោង ដើម្បីផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់ទ្រព្យសម្បត្តិគម្រោងស្របច្បាប់ឱ្យបានស្មើភាពគ្នានិងមិនត្រូវរើសអើងឬបដិសេធការផ្តល់សេវាកម្មដល់អ្នកប្រើប្រាស់ណាដែលបានយល់ព្រមបង់ថ្លៃប្រើប្រាស់ទ្រព្យសម្បត្តិគម្រោង តាមតម្លៃដែលបានផ្សព្វផ្សាយជាសាធារណៈឡើយ។

២- ធានាថាទ្រព្យសម្បត្តិគម្រោងអាចប្រតិបត្តិការបាននិងអាចទទួលការប្រើប្រាស់បានតាមបទដ្ឋានបច្ចេកទេសនិងបទដ្ឋានយថាប្រភេទ ដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៣- ធ្វើការផ្គត់ផ្គង់ផលិតផលនិង/ឬសេវាកម្មទៅតាមបរិមាណ គុណភាព និងរយៈពេលដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៤- កាតព្វកិច្ចផ្សេងទៀតដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

មាត្រា៤០ .-

ស្ថាប័នសាមីត្រូវទទួលខុសត្រូវចំពោះការងារគ្រប់គ្រង តាមដាន និងរៀបចំរបាយការណ៍វឌ្ឍនភាពគម្រោង របាយការណ៍ក្រោយបញ្ចប់គម្រោង និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀត ស្របតាមកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ. ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំជារបាយការណ៍រួមជូនរាជរដ្ឋាភិបាល ដើម្បីធានាថាការអនុវត្តរបស់គូភាគី អនុលោមតាមខនិងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ក្នុងការអនុវត្តការទទួលខុសត្រូវនេះ ស្ថាប័នសាមីអាចរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងគម្រោង ដែលអាចមានការគាំទ្រពីស្ថាប័នសាធារណៈពាក់ព័ន្ធនិងទីប្រឹក្សាក្នុងផ្នែកពាក់ព័ន្ធ មានជាអាទិ៍ផ្នែកបច្ចេកទេស ច្បាប់ ហិរញ្ញវត្ថុ និងការគ្រប់គ្រងកិច្ចសន្យា។

ដៃគូឯកជនត្រូវទទួលខុសត្រូវចំពោះការរៀបចំរបាយការណ៍ជូនស្ថាប័នសាមីនិងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីស្ថានភាព វឌ្ឍនភាព និងសមិទ្ធកម្មនៃការអនុវត្តគម្រោង រួមបញ្ចូលទាំងសមិទ្ធកម្មហិរញ្ញវត្ថុ តាមតម្រូវការដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ជំពូកទី១០
រយៈពេលនៃកិច្ចសន្យា ការរំលាយកិច្ចសន្យា និងការប្រគល់ទ្រព្យសម្បត្តិគម្រោងជូនរដ្ឋវិញ

មាត្រា៤១ .-

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់រយៈពេលនៃកិច្ចសន្យានិងលក្ខខណ្ឌពន្យាររយៈពេលនៃកិច្ចសន្យា។ ការកំណត់រយៈពេលដំបូងបង្អស់នៃកិច្ចសន្យាភ.រ.ជ. ត្រូវផ្អែកទៅលើកត្តាអាយុកាលនៃទ្រព្យសម្បត្តិគម្រោង និងកត្តាពេលវេលា ដែលដៃគូឯកជនត្រូវការដើម្បីរំលស់ថ្លៃដើមនៃការវិនិយោគ។ រយៈពេលដំបូងបង្អស់នៃកិច្ចសន្យាភ.រ.ជ. មិនត្រូវលើសពី៣០(សាមសិប)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចុះកិច្ចសន្យា។ ក្នុងករណីចាំបាច់ ដោយយោងតាមប្រភេទនៃគម្រោងភ.រ.ជ. រាជរដ្ឋាភិបាលអាចកំណត់រយៈពេលដំបូងបង្អស់នៃកិច្ចសន្យាលើសពី៣០(សាមសិប)ឆ្នាំ។

មាត្រា៤២ .-

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់ករណីដែលអាចរំលាយកិច្ចសន្យាមុនពេលកំណត់ មានជាអាទិ៍ក្នុងករណីភាគីណាមួយមិនបានបំពេញតាមកាតព្វកិច្ចរបស់ខ្លួន ករណីប្រធានសក្តិនិង/ឬករណីដែលរាជរដ្ឋាភិបាលរំលាយកិច្ចសន្យាមុនពេលកំណត់។

កិច្ចសន្យាភ.រ.ជ. ត្រូវកំណត់សិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីដែលត្រូវបំពេញ យន្តការ និងរូបមន្តគណនាការទូទាត់សំណងសម្រាប់ការរំលាយកិច្ចសន្យាមុនពេលកំណត់។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

មាត្រា៤៣ .-

ក្នុងករណីដៃគូឯកជនមានកាតព្វកិច្ចប្រគល់ទ្រព្យសម្បត្តិគម្រោងជូនរដ្ឋវិញ កិច្ចសន្យាភ.រ.ជ. ត្រូវបញ្ជាក់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការប្រគល់ទទួលទ្រព្យសម្បត្តិគម្រោងនោះ។ នៅពេលប្រគល់ទ្រព្យសម្បត្តិគម្រោងជូនរដ្ឋវិញ ដៃគូឯកជនត្រូវធានាថាទ្រព្យសម្បត្តិគម្រោងនោះមានលក្ខណៈត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

ការប្រគល់ទទួលទ្រព្យសម្បត្តិគម្រោង ត្រូវអនុវត្តតាមគោលការណ៍ណែនាំសម្រាប់គ្រប់គ្រងកិច្ចសន្យា ដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

ជំពូកទី១១
ការដោះស្រាយវិវាទ

មាត្រា៤៤ .-

វិវាទទាំងឡាយណាដែលកើតឡើងរវាងស្ថាប័នសាមីនិងដៃគូឯកជន ពាក់ព័ន្ធនឹងកិច្ចសន្យាភ.រ.ជ.ត្រូវដោះស្រាយទៅតាមយន្តការដោះស្រាយវិវាទដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

មាត្រា៤៥ .-

ក្នុងករណីកិច្ចសន្យាភ.រ.ជ.ឬកិច្ចព្រមព្រៀងសម្បទានមិនមានចែងពីយន្តការដោះស្រាយវិវាទ វិវាទដែលកើតឡើងរវាងស្ថាប័នសាមីនិងដៃគូឯកជន ពាក់ព័ន្ធនឹងកិច្ចសន្យាភ.រ.ជ. ឬកិច្ចព្រមព្រៀងសម្បទាន ត្រូវដោះស្រាយតាមរយៈការពិគ្រោះគ្នារវាងស្ថាប័នសាមីនិងដៃគូឯកជន ក្រោមការសម្រុះសម្រួលដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លី។

ក្នុងរយៈពេល២(ពីរ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូងពីភាគីណាមួយដែលស្នើសុំធ្វើការសម្រុះសម្រួលគ្នា ប្រសិនបើគូភាគីមិនអាចដោះស្រាយវិវាទតាមការសម្រុះសម្រួលគ្នាទេ គូភាគីអាចព្រមព្រៀងលើកយកវិវាទនោះទៅដោះស្រាយនៅមជ្ឈត្តការពាណិជ្ជកម្មកម្ពុជាឬមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិណាមួយ។ ក្នុងករណីដែលគូភាគីមិនព្រមដោះស្រាយតាមរយៈមជ្ឈត្តការពាណិជ្ជកម្មកម្ពុជាឬមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ ភាគីណាមួយអាចប្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី១២
ទោសប្បញ្ញត្តិ

មាត្រា៤៦ .-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលរងទណ្ឌកម្មតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

នីតិបុគ្គលក៏ត្រូវទទួលទណ្ឌកម្មស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផងដែរ ក្នុងករណីដែលមន្ត្រី បុគ្គលិក ឬភ្នាក់ងារក្រោមឱវាទរបស់ខ្លួន ធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារខ្លួនដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ។

មន្ត្រីរាជការដែលអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនដោយល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលរងទណ្ឌកម្មខាងវិន័យស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌនិងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត។

ជំពូកទី១៣
អន្តរប្បញ្ញត្តិ

មាត្រា៤៧ .-

ច្បាប់នេះមិនមានអានុភាពអនុវត្តចំពោះគម្រោងអាទិភាពដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលមុនច្បាប់នេះចូលជាធរមាន។ យន្តការនិងនីតិវិធីនៃការរៀបចំអភិវឌ្ឍគម្រោងអាទិភាពនេះត្រូវបន្តរហូតដល់ចប់ ដោយផ្អែកតាមយន្តការនិងនីតិវិធីដែលបានអនុវត្តនៅមុនពេលច្បាប់នេះចូលជាធរមាន។

ក្រៅតែពីបទប្បញ្ញត្តិទាក់ទងនឹងការដោះស្រាយវិវាទដូចមានចែងក្នុងជំពូកទី១១នៃច្បាប់នេះ បទប្បញ្ញត្តិដទៃទៀតនៃច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជនមិនមានអានុភាពអនុវត្តចំពោះកិច្ចព្រមព្រៀងសម្បទាន ឬកិច្ចសន្យាដែលមានលក្ខណៈប្រហាក់ប្រហែលនឹងកិច្ចសន្យាភ.រ.ជ. ដែលបានចុះហត្ថលេខាមុនច្បាប់នេះចូលជាធរមាននោះទេ។

ជំពូកទី១៤
អវសានប្បញ្ញត្តិ

មាត្រា៤៨ .-

ច្បាប់ស្តីពីសម្បទានដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា៤៩ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២១

នស/រកម/១១២១/០០៤

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ឧបសម្ព័ន្ធ១

សទ្ទានុក្រម

១- **ការគាំទ្រពីរដ្ឋ** សំដៅដល់ជំនួយហិរញ្ញវត្ថុនិងជំនួយមិនមែនហិរញ្ញវត្ថុដែលរដ្ឋផ្តល់ដើម្បីគាំទ្រការអនុវត្តគម្រោងភ.រ.ជ.។ ការគាំទ្រពីរដ្ឋមានជាអាទិ៍ថវិកាសម្រាប់គម្រោងផ្ទាល់ដែលរាជរដ្ឋាភិបាលបានធានាចំណាយ(ដូចជាការឧបត្ថម្ភធន) កាតព្វកិច្ចបំណុលជាយថាហេតុ (ដូចជាកិច្ចធានាផ្សេងៗ) វិភាគទានជាទ្រព្យសម្បត្តិរដ្ឋនិងជំនួយក្នុងទម្រង់ផ្សេងទៀត។

២- **ការចុះកិច្ចសន្យាផ្ទាល់** សំដៅដល់វិធីសាស្ត្រលទ្ធកម្មជ្រើសរើសដៃគូឯកជនដែលតម្រូវឱ្យចរចាកិច្ចសន្យាផ្ទាល់ជាមួយបេក្ខភាពដៃគូឯកជន ដើម្បីអនុវត្តគម្រោងភ.រ.ជ.។

៣- **ការបំពេញផលហិរញ្ញវត្ថុ** សំដៅដល់ការគាំទ្រពីរដ្ឋមួយប្រភេទដែលជាការឧបត្ថម្ភធនដោយផ្ទាល់ដល់ការចំណាយមូលធនក្រោមក្របខ័ណ្ឌគម្រោងភ.រ.ជ. ដើម្បីបង្កើនផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោងនោះចំពោះដៃគូឯកជន។

៤- **ការសិក្សាសមិទ្ធិលទ្ធភាព** សំដៅដល់ការសិក្សាអំពីលទ្ធភាពអនុវត្តកិច្ចលទ្ធកម្មនិងអនុវត្តគម្រោងតាមយន្តការភ.រ.ជ.។ ការសិក្សាសមិទ្ធិលទ្ធភាពត្រូវមានការពិនិត្យលើទិដ្ឋភាពបច្ចេកទេស ច្បាប់ ទីផ្សារ ពាណិជ្ជកម្ម សេដ្ឋកិច្ច ហិរញ្ញវត្ថុ បរិស្ថាន និងសង្គម ព្រមទាំងមានការវិភាគលើជម្រើសប្រភេទគម្រោងភ.រ.ជ. ការវាយតម្លៃហានិភ័យនានា ការបែងចែកការទទួលបន្ទុកលើហានិភ័យរវាងភាគីរដ្ឋនិងដៃគូឯកជន និងការវាយតម្លៃលើតម្រូវការនៃការគាំទ្រពីរដ្ឋ។

៥- **កិច្ចព្រមព្រៀងវិនិយោគ** សំដៅដល់កិច្ចព្រមព្រៀងដែលគូភាគីនៃកិច្ចសន្យាភ.រ.ជ. និងក្រុមហ៊ុនមានគោលបំណងពិសេសត្រូវចុះហត្ថលេខាដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្ទេរសិទ្ធិនិងកាតព្វកិច្ចទាំងស្រុងរបស់ដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ជ. ជូនក្រុមហ៊ុនមានគោលបំណងពិសេស ដោយរក្សាខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ. ដដែល។

៦- **កិច្ចព្រមព្រៀងបន្ទាប់បន្សំ** សំដៅដល់កិច្ចព្រមព្រៀងដែលបានធ្វើឡើងរវាងដៃគូឯកជននិងអ្នកម៉ៅការ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ដៃគូឯកជន តាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ស្ថាប័នសាមីមិនតម្រូវឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ទាប់បន្សំនោះទេ ប៉ុន្តែត្រូវពិនិត្យនិងផ្តល់យោបល់លើកិច្ចព្រមព្រៀងនោះ ដើម្បីធានាសង្គតិភាពជាមួយនឹងខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ.។

៧- **កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការអនុវត្តគម្រោងភ.រ.ជ.** សំដៅដល់កិច្ចព្រមព្រៀងដែលបានធ្វើឡើងរវាងស្ថាប័នសាធារណៈ ជាភាគីនៃកិច្ចព្រមព្រៀងជាមួយដៃគូឯកជនណាមួយ ដើម្បីគាំទ្រដល់ការអនុវត្តគម្រោងភ.រ.ជ. ពាក់ព័ន្ធជាអាទិ៍នឹងការសាងសង់ ហិរញ្ញប្បទាន ប្រតិបត្តិការ និងការថែទាំ។

៨- **កិច្ចព្រមព្រៀងសម្បទាន** សំដៅដល់កិច្ចព្រមព្រៀងស្របតាមច្បាប់ស្តីពីសម្បទាន។

៩- **កិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន** សំដៅដល់កិច្ចព្រមព្រៀងរវាងស្ថាប័នសាមីនិងដៃគូឯកជន ដែលមានចែងនូវខនិងលក្ខខណ្ឌសម្រាប់អនុវត្តគម្រោងភ.រ.ជ.។ ប្រភេទគម្រោងភ.រ.ជ.ទូទៅ សម្រាប់ជាមូលដ្ឋានក្នុងការកំណត់ទម្រង់នៃកិច្ចសន្យាភ.រ.ជ. មានចែងក្នុងឧបសម្ព័ន្ធ២នៃច្បាប់នេះ។

១០- **ក្រុមហ៊ុនមានគោលបំណងពិសេស** សំដៅដល់សហគ្រាសដែលត្រូវបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា ដោយវិនិយោគិន ស្របតាមខនិងលក្ខខណ្ឌនៃកិច្ចសន្យាភ.រ.ជ. ដោយអនុលោមតាមមាត្រា២២នៃច្បាប់នេះ ដើម្បីធ្វើជាដៃគូឯកជនក្នុងកិច្ចសន្យាភ.រ.ជ. ក្នុងការអនុវត្តគម្រោងភ.រ.ជ.។

១១- **គម្រោងផ្តួចផ្តើមដោយរដ្ឋ** សំដៅដល់គម្រោងដែលត្រូវបានស្នើឡើងរៀបចំនិងការពារដោយស្ថាប័នសាមីនិងមានសក្តានុពលអនុវត្តតាមយន្តការភ.រ.ជ.។ ប្រសិនបើគម្រោងនេះត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ស្ថាប័នសាមីនឹងត្រូវចេញសេចក្តីជូនដំណឹងអំពីការអញ្ជើញដាក់សំណើគម្រោង ដើម្បីជ្រើសរើសដៃគូឯកជន ដោយអនុលោមតាមជំពូកទី៦នៃច្បាប់នេះ។

១២- **គម្រោងផ្តួចផ្តើមដោយឯកជន** សំដៅដល់គម្រោងដែលមានសក្តានុពលអនុវត្តតាមយន្តការភ.រ.ជ. ត្រូវបានស្នើឡើងដោយវិស័យឯកជន តាមរយៈស្ថាប័នសាមី។

១៣- **គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ** សំដៅដល់គំនូរប្លង់ ការសាងសង់ការថែទាំ ឬការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធថ្មី ឬការធ្វើទំនើបភាវូបនីយកម្ម ការពង្រីកការគ្រប់គ្រង ឬការធ្វើអាជីវកម្មនៃសំណង់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។

១៤- **គម្រោងសេវាសាធារណៈ** សំដៅដល់សេវាដែលត្រូវផ្តល់ដោយស្ថាប័នសាធារណៈតាមមុខងារនិងភារកិច្ចជាធរមាន ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ជូនដល់សាធារណជនជារូបវន្តបុគ្គលឬនីតិបុគ្គល។ សកម្មភាពនេះអាចកាន់កាប់ដោយរដ្ឋខ្លួនឯងឬអាចប្រគល់ឱ្យឯកជនកាន់កាប់ ប៉ុន្តែស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ។

១៥- **គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន** សំដៅដល់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិង/ឬគម្រោងផ្តល់សេវាសាធារណៈ ដែលអនុវត្តក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ. ដោយអនុលោមតាមច្បាប់នេះ។

១៦- **ដៃគូឯកជន** សំដៅដល់បុគ្គលដែលបានចុះកិច្ចសន្យាភ.រ.ជ. ជាមួយស្ថាប័នសាមី។ ក្នុងករណីក្រុមហ៊ុនមានគោលបំណងពិសេស ត្រូវបានបង្កើតឡើងដោយអនុលោមតាមមាត្រា២២នៃច្បាប់នេះ ដៃគូឯកជនសំដៅដល់ក្រុមហ៊ុនមានគោលបំណងពិសេសនេះវិញ។

១៧- **តម្លៃនៃលុយ** សំដៅដល់ផលចំណេញដែលអាចកើតឡើងចំពោះរដ្ឋ ដោយសារការអនុវត្តគម្រោងណាមួយ តាមរយៈយន្តការភ.រ.ជ. ជាជាងតាមរយៈលទ្ធកម្មសាធារណៈ។

ផលចំណេញនេះអាចវាយតម្លៃ តាមរយៈការវិភាគតាមបែបគុណភាពនិង/ឬតាមបែបបរិមាណលើផលប្រយោជន៍និងចំណាយរបស់រដ្ឋ ក្នុងអាយុកាលទាំងស្រុងនៃគម្រោង។ គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃនេះ ត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

១៨- ទីប្រឹក្សា សំដៅដល់ក្រុមហ៊ុនទីប្រឹក្សា ជំនាញការ និង/ឬអ្នកផ្ដល់សេវាដែលមានបទពិសោធន៍ ជាអាទិ៍ផ្នែកហិរញ្ញវត្ថុ ច្បាប់ និងបច្ចេកទេស ក្នុងការរៀបចំអភិវឌ្ឍ និងអនុវត្តគម្រោង ភ.រ.ជ.។

១៩- ទ្រព្យសម្បត្តិគម្រោង សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តឬប្រព័ន្ធដែលនឹងត្រូវសាងសង់និង/ឬប្រតិបត្តិការ ក្រោមក្របខ័ណ្ឌកិច្ចសន្យាភ.រ.ជ. ដើម្បីផ្ដល់សេវាសាធារណៈដោយផ្ទាល់ឬដោយប្រយោល។

២០- បញ្ជីគម្រោងអាទិភាពក្នុងក្របខ័ណ្ឌគម្រោងភ.រ.ជ. សំដៅដល់បញ្ជីគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលជាគម្រោងស្ថាប័នសាមីបានធ្វើអត្តសញ្ញាណកម្មនិងអាទិភាវូបនីយកម្ម រួចបានជ្រើសរើសដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមមាត្រា១០នៃច្បាប់នេះ។

២១- ភាពជាដៃគូរវាងរដ្ឋនិងឯកជន សំដៅដល់កិច្ចព្រមព្រៀងរវាងភាគីរដ្ឋនិងដៃគូឯកជន ដើម្បីធ្វើការងារស្ដារ ជួសជុល ពង្រីក សាងសង់ ប្រតិបត្តិការនិង/ឬថែទាំលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬទ្រព្យសម្បត្តិគម្រោង ឬដើម្បីផ្ដល់សេវាសាធារណៈ ក្នុងអំឡុងពេលកំណត់ណាមួយ។ ក្នុងកិច្ចព្រមព្រៀងនេះ ដៃគូឯកជនត្រូវធ្វើការវិនិយោគ ទទួលបន្ទុកហានិភ័យមួយចំណែកនិងទទួលអត្ថប្រយោជន៍ផ្អែកទៅលើសមិទ្ធកម្ម តាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

២២- ម្ចាស់សំណើគម្រោងផ្ដួចផ្ដើមដោយឯកជន សំដៅដល់បុគ្គលដែលរៀបចំសំណើគម្រោងផ្ដួចផ្ដើមដោយឯកជន ដោយអនុលោមតាមមាត្រា២៣នៃច្បាប់នេះ។

២៣- មូលនិធិអភិវឌ្ឍន៍គម្រោង សំដៅដល់យន្តការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលប្រើប្រាស់ថវិកាជាតិនិងថវិកាពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីផ្ដល់ហិរញ្ញប្បទានសម្រាប់ចំណាយលើការសិក្សារៀបចំអភិវឌ្ឍគម្រោង ធ្វើកិច្ចលទ្ធកម្មនិងការងារពាក់ព័ន្ធផ្សេងទៀត ដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

២៤- វិនិយោគិន សំដៅដល់បុគ្គលដែលផ្ដល់ហិរញ្ញប្បទានជាភាគទុនដល់ដៃគូឯកជន ដើម្បីអនុវត្តកិច្ចសន្យាភ.រ.ជ. ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

២៥- សិទ្ធិចូលអន្តរាគមន៍ សំដៅដល់សិទ្ធិដែលផ្ដល់ជូនដល់អ្នកផ្ដល់ប្រាក់កម្ចីនិង/ឬរាជរដ្ឋាភិបាល ដើម្បីចូលគ្រប់គ្រងកិច្ចសន្យាភ.រ.ជ. ក្នុងរយៈពេលណាមួយ ក្នុងករណីដែលដៃគូឯកជនឬក្រុមហ៊ុនមានគោលបំណងពិសេស មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដែលប៉ះពាល់ធ្ងន់ធ្ងរដល់និរន្តរភាពនៃការអនុវត្តគម្រោងភ.រ.ជ.។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS *

២៦- **សិទ្ធិប្រត្យក្ស** សំដៅដល់សិទ្ធិដែលមាននិយមន័យដូចបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

២៧- **ស្ថាប័នសាមី** សំដៅដល់ក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវចំពោះការអភិវឌ្ឍគម្រោងនិង/ឬដែលដើរតួជាភាគីរដ្ឋក្នុងការចុះកិច្ចសន្យាភ.រ.ជ. ជាមួយនឹងដៃគូឯកជនសម្រាប់ការអនុវត្តគម្រោងភ.រ.ជ.។

២៨- **សំណើគម្រោងផ្តួចផ្តើមដោយឯកជន** សំដៅដល់ការស្នើសុំជាលាយលក្ខណ៍អក្សររបស់ម្ចាស់សំណើគម្រោងផ្តួចផ្តើមដោយឯកជនជូនចំពោះស្ថាប័នសាមី ដើម្បីរៀបចំអភិវឌ្ឍគម្រោងថ្មីជាគម្រោងភ.រ.ជ. ដែលផ្តល់នូវទស្សនាទានថ្មី បច្ចេកវិទ្យាថ្មី ឬនវានុវត្តន៍ ដល់ព្រះរាជាណាចក្រកម្ពុជា។

២៩- **អ្នកម៉ៅការ** សំដៅដល់ក្រុមហ៊ុនម៉ៅការ អ្នកផ្គត់ផ្គង់ ឬអ្នកផ្តល់សេវា ដែលបានជ្រើសរើសដោយដៃគូឯកជន ដើម្បីគាំទ្រដល់ការអនុវត្តកិច្ចសន្យាភ.រ.ជ.។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឧបសម្ព័ន្ធ២

ប្រភេទគម្រោងភ.រ.ជ. ដែលមានការប្រើប្រាស់ជាទូទៅ

១- **សាងសង់ ធ្វើប្រតិបត្តិការ និងផ្ទេរ** : ស្ថាប័នសាមីផ្តល់សិទ្ធិជូនដៃគូឯកជន ដើម្បីរចនាប្លង់ ហិរញ្ញប្បទាន សាងសង់ ធ្វើប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិគម្រោង ហើយប្រមូលកម្រៃសេវាថ្លៃប្រើប្រាស់ ថ្លៃឈ្នួល និងថ្លៃផ្សេងទៀត ពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឬអ្នកប្រើប្រាស់ សេវារបស់គម្រោង ក្នុងរយៈពេលដូចបានកំណត់ក្នុងកិច្ចសន្យាភ.រ.ជ.។ ក្រោយពីការបញ្ចប់រយៈពេល នៃកិច្ចសន្យា ដៃគូឯកជនត្រូវផ្ទេរសិទ្ធិនិងអត្ថប្រយោជន៍ដែលជាប់ពាក់ព័ន្ធនឹងគម្រោង ព្រមទាំងទ្រព្យសម្បត្តិគម្រោងឱ្យទៅស្ថាប័នសាមីវិញ ដោយអនុលោមតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ប្រភេទគម្រោងភ.រ.ជ. ដែលមានទម្រង់បែបប្រភេទគម្រោង**សាងសង់ ធ្វើប្រតិបត្តិការ និងផ្ទេរ**ដែរ មានជាអាទិ៍៖

- **សាងសង់ ជួល និងផ្ទេរ** : ដៃគូឯកជនត្រូវរចនាប្លង់ ហិរញ្ញប្បទាន និងសាងសង់ទ្រព្យសម្បត្តិគម្រោង ហើយបន្ទាប់មកដាក់ទ្រព្យសម្បត្តិគម្រោងនោះជួលទៅឱ្យស្ថាប័នសាមីវិញ ដោយទទួលបានកម្រៃ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ប្រភេទគម្រោងនេះរក្សាលក្ខខណ្ឌផ្សេងទៀតនៃប្រភេទគម្រោង**សាងសង់ ធ្វើប្រតិបត្តិការ និងផ្ទេរ** នៅដដែល។
- **សាងសង់ ផ្ទេរ និងធ្វើប្រតិបត្តិការ**: ក្រោយពេលបញ្ចប់ការងារសាងសង់ទ្រព្យសម្បត្តិគម្រោង ដៃគូឯកជនត្រូវផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិគម្រោងនោះ ទៅឱ្យស្ថាប័នសាមីជាមុនសិន។ ប្រភេទគម្រោងនេះរក្សាលក្ខខណ្ឌផ្សេងទៀតនៃប្រភេទគម្រោង**សាងសង់ ធ្វើប្រតិបត្តិការ និងផ្ទេរ**នៅដដែល។

២- **សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ ធ្វើប្រតិបត្តិការ និងផ្ទេរ** : ស្ថាប័នសាមីផ្តល់សិទ្ធិជូនដៃគូឯកជន ដើម្បីរចនាប្លង់ ហិរញ្ញប្បទាន សាងសង់ ធ្វើប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិគម្រោង ហើយប្រមូលកម្រៃសេវា ថ្លៃប្រើប្រាស់ ថ្លៃឈ្នួល និងថ្លៃផ្សេងទៀត ពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ឬអ្នកប្រើប្រាស់សេវារបស់គម្រោង ក្នុងរយៈពេលដូចបានកំណត់ក្នុងកិច្ចសន្យាភ.រ.ជ.។ ប្រភេទគម្រោង**សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ ធ្វើប្រតិបត្តិការ និងផ្ទេរ** ខុសពីប្រភេទគម្រោង**សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ ធ្វើប្រតិបត្តិការ និងផ្ទេរ** ត្រង់ដៃគូឯកជនធ្វើជាម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិគម្រោងក្នុងរយៈពេលនៃកិច្ចសន្យា។ ក្រោយពីការបញ្ចប់រយៈពេលនៃកិច្ចសន្យា ដៃគូឯកជនត្រូវផ្ទេរសិទ្ធិនិងអត្ថប្រយោជន៍ដែលជាប់ពាក់ព័ន្ធនឹងគម្រោង ព្រមទាំងទ្រព្យសម្បត្តិគម្រោងទៅឱ្យស្ថាប័នសាមីវិញ ដោយអនុលោមតាមខនិងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៣- **សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ** : ស្ថាប័នសាមីផ្តល់សិទ្ធិជូនដៃគូឯកជន ដើម្បីរចនាប្លង់ ហិរញ្ញប្បទាន សាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការលើទ្រព្យសម្បត្តិគម្រោងជាអចិន្ត្រៃយ៍ ឬក្នុងរយៈពេលមិនកំណត់ ស្របតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ដៃគូឯកជនមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិគម្រោងជាលក្ខណៈពាណិជ្ជកម្ម

ហើយមានសិទ្ធិប្រមូលកម្រៃនិងចំណូលផ្សេងទៀត ពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធឬអ្នកប្រើប្រាស់សេវារបស់គម្រោង។ ប្រភេទគម្រោងភ.រ.ជ. ដែលមានទម្រង់បែបប្រភេទគម្រោងសាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការដែរ មានជាអាទិ៍៖

- **ស្ដារនីតិសម្បទា ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ**: ប្រភេទគម្រោងនេះមានលក្ខខណ្ឌដូចប្រភេទគម្រោងសាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការដែរ តែដៃគូឯកជនត្រូវទទួលសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិគម្រោងដែលមានស្រាប់ដើម្បីធ្វើការស្ដារនីតិសម្បទានៃទ្រព្យសម្បត្តិគម្រោងនោះ។

- **ទំនើបភាវូបនីយកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការ** : ប្រភេទគម្រោងនេះមានលក្ខខណ្ឌដូចប្រភេទគម្រោងសាងសង់ ធ្វើជាម្ចាស់កម្មសិទ្ធិ និងធ្វើប្រតិបត្តិការដែរ តែដៃគូឯកជនត្រូវទទួលសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិគម្រោងដែលមានស្រាប់ដើម្បីធ្វើទំនើបភាវូបនីយកម្មលើទ្រព្យសម្បត្តិគម្រោងនោះ។

៤- **កិច្ចព្រមព្រៀងស្ដីពីការគ្រប់គ្រង/កិច្ចព្រមព្រៀងស្ដីពីប្រតិបត្តិការ និងការថែទាំ** : ដៃគូឯកជនត្រូវផ្ដល់សេវាកម្មប្រចាំថ្ងៃ ដែលពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការ និងការថែទាំលើទ្រព្យសម្បត្តិគម្រោងដែលមានស្រាប់ ឬទ្រព្យសម្បត្តិរដ្ឋផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ស្ថាប័នសាមី ដោយទទួលបានកម្រៃសេវាពីស្ថាប័នសាមីឬភាគីផ្សេងទៀត ស្របតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ជាទូទៅ កិច្ចសន្យាបែបនេះមិនតម្រូវឱ្យដៃគូឯកជនចំណាយមូលធនរបស់ខ្លួនដើម្បីធ្វើការវិនិយោគនិងមិនផ្ដល់កម្មសិទ្ធិលើទ្រព្យសម្បត្តិគម្រោង ឬទ្រព្យសម្បត្តិរដ្ឋណាមួយជូនដៃគូឯកជនឡើយ។ ក្នុងករណីដែលគម្រោងតម្រូវឱ្យដៃគូឯកជនចំណាយមូលធនរបស់ខ្លួន ដើម្បីធ្វើការវិនិយោគនោះ ដៃគូឯកជនអាចរំលស់ថ្លៃដើមនៃការវិនិយោគនេះតាមរយៈការទូទាត់ពីស្ថាប័នសាមីឬពីភាគីផ្សេងទៀត តាមខនិងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៥- **រចនាប្លង់ សាងសង់ ហិរញ្ញប្បទាន ធ្វើប្រតិបត្តិការ និងថែទាំ** : ស្ថាប័នសាមីផ្ដល់សិទ្ធិជូនដៃគូឯកជន ដើម្បីរចនាប្លង់ សាងសង់ ហិរញ្ញប្បទាន ផ្ដល់សេវាកម្មប្រតិបត្តិការ និងសេវាកម្មថែទាំ ចំពោះទ្រព្យសម្បត្តិគម្រោង ដោយអនុលោមតាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យា ភ.រ.ជ.។ ដៃគូឯកជនមានសិទ្ធិប្រមូលប្រាក់ចំណូល ពីការផ្ដល់សេវាកម្មខាងលើ តាមរយៈការទូទាត់ពីស្ថាប័នសាមី ឬភាគីផ្សេងទៀត តាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។ ក្រោយពីការបញ្ចប់រយៈពេលនៃកិច្ចសន្យា ដៃគូឯកជនត្រូវផ្ទេរទ្រព្យសម្បត្តិគម្រោងទៅឱ្យស្ថាប័នសាមីវិញ។

៦- **រចនាប្លង់ សាងសង់ និងជួល** : ស្ថាប័នសាមីផ្ដល់សិទ្ធិជូនដៃគូឯកជនដើម្បីរចនាប្លង់ សាងសង់ និងជួលទ្រព្យសម្បត្តិគម្រោងពីស្ថាប័នសាមី ធ្វើប្រតិបត្តិការ និងសេវាកម្មថែទាំ តាមខនិងលក្ខខណ្ឌ ដូចមានចែងក្នុងកិច្ចសន្យាភ.រ.ជ.។

៧- **ប្រភេទគម្រោងភ.រ.ជ.ផ្សេងទៀត។**

ព្រះរាជក្រឹត្យ

នស/រកត/១១២១/ ៧៧៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ុង អ៊ីនម៉ូ** (SUNG INMO) ជនជាតិ កូរ៉េ សញ្ជាតិ កូរ៉េ កើតនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៨៨ នៅរដ្ឋធានីសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ស៊ុង សែន** (SUNG SEN)។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៖ណ.២១១១.៧៧៤៦

នសីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១១២១/៧៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឈិន ឈានជីន** (CHEN QUAN JIN) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៨៥ នៅខេត្តហ្វ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៧៥៣-៤១១១.៧៨៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២១

នសីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១១២១/៧៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ថាំង វ៉េម៉ៅ** (TANG, WEIMAO) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧០ នៅខេត្ត Guangdong សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ចារលិ.២១១១.៧៥៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១១២១/៧៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **ជាតូបការ** :

១- ឯកឧត្តម	**ខូច លី**	២- ឯកឧត្តម	**សុខ ប្រសិទ្ធិ**
៣- លោក	**សន សេត**	៤- លោក	**ហេង រតនា**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម	**សំរិត ឡឿន**	២- លោកស្រី	**ណាង សុវណ្ណា**
៣- លោក	**វ៉ាង ចាន់តិរិទ្ធ**	៤- លោក	**ហែម សាម៉ន**
៥- លោក	**សុខ ឧុទ្ធី**	៦- លោក	**ឡូ ជីវែង**
៧- លោក	**អ៊ុង មន្នីរិទ្ធ**	៨- លោក	**រស់ ស៊ីសុវណ្ណា**
៩- លោក	**ឃីម ផល្លា**	១០- លោក	**ផៃ សុផល**
១១- លោក	**ស្វាយ ប៊ូរ៉ា**	១២- ឯកឧត្តម	**កុក យូឡេង**
១៣- លោកជំទាវ	**លី ផុស្សតី**	១៤- លោកជំទាវ	**ឃឹម សុផាន់ណារី**
១៥- លោកស្រី	**សុខ គន្ធា**	១៦- លោក	**សុខ គឹមជ**
១៧- លោក	**អ៊ុក គន្ធា**	១៨- លោកគ្រូពេទ្យ	**សៅ កុសល**
១៩- លោក	**ផាត់ វ៉ាឌុធ**	២០- លោក	**អ៊ួន ចាន់ថន**
២១- លោក	**ថន វណ្ណា:**	២២- លោកស្រី	**ឡុង សំរេច**

គ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោក	**ព្រុំ សំណាង**	២- លោក	**សៀក សីហាន**
៣- លោក	**ចាន់ រិទ្ធី**	៤- លោក	**ផន រឹម**
៥- លោក	**មាន ចន្ធា**	៦- លោក	**សៀង សេង**

ឃ- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- Mr. NOPPARAT CHATPECHTRAKARN	២- Mr. KITTISAK LERTJANTHARANGKUN
៣- Miss. SUNTAREE SRISUWAN	

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ង- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- លោក **ឡូយ បញ្ញា**
២- លោក **អយ សុជាតិ**
៣- លោក **អៀម សារ៉េ**
៤- Mr. DINH VAN NOI
៥- លោក **ជួន លឹមហេង**
៦- លោក **ឯក ផល្លា**
៧- លោក **នូ ប៉ូរ៉ានី**

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- លោក **គង់ ថូ**
២- លោក **អ៊ឹម លី**
៣- លោក **យ៉ង់ សំបូរ**
៤- លោក **ឈើយ លនទណ្ណារិទ្ធិ**
៥- លោក **អ៊ុំ រាត្រីប្រសើរ**
៦- លោក **កែវ ធីរៈ**
៧- លោក **ផាន់ ដារ៉ា**
៨- លោក **សូស រិទ្ធី**
៩- លោក **ផាយ ផល្លា**
១០- លោក **ពិន អូន**
១១- លោក **ទ្រេង សុខឆាយ**
១២- លោក **សេក សេង**
១៣- អ្នកអង្គ **ស៊ីសុវត្ថិ បញ្ញាមុន្នី**
១៤- លោក **អ៊ុន ពិសិដ្ឋ**
១៥- លោក **ខេង សេងឡុង**
១៦- លោក **អេម ពៅ**
១៧- លោក **កែវ សាងផលបុណ្យ**
១៨- លោក **មូល កោសិន្ត**
១៩- លោក **ហេង វ៉ាន់ធី**
២០- លោក **ជា ហេងឡុង**
២១- លោកស្រី **អឿ គឹមសាន់**
២២- លោកស្រី **ស៊ីថា នីតជាវឌី**
២៣- លោក **គួរ ប្រុស**
២៤- លោកស្រី **កែវ សោភ័ណា**

នស.រកត.១១២១.១៣៤៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២១

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១១២១/៣៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **ជាតូបការ** :

១- លោកជំទាវ	**ឌួង ម៉ុណ្ណាលីន**	២- បណ្ឌិត	**អ៊ុក ភ័ក្ត្រា**
៣- ឧកញ៉ា	**រស់ ផល្លា**		

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោក	**អ៊ូ ជួបកុសល**	២- លោក	**ហ៊ឹត ផល្លា**
៣- លោក	**សា ចាន់រ៉ាត់**	៤- លោក	**ហង់ តារម្យ**
៥- លោក	**ឯម វឌ្ឍនា**	៦- លោក	**ថន ច័ន្ទសុវណ្ណា**
៧- លោកស្រី	**ចាន់ លីណា**	៨- លោក	**ជា វណ្ណា**
៩- លោក	**ឆន ម៉េងលី**	១០- លោក	**ផុន ឆៃយ៉ា**
១១- លោក	**រស់ វឌ្ឍរតនៈ**	១២- លោក	**ជា កុសល្យ**
១៣- លោក	**គេង សួរ**	១៤- លោក	**អ៊ុក ច័ន្ទរិទ្ធី**
១៥- លោក	**ទុយ សុខនៅ**	១៦- លោក	**ជា ស៊ីណាន់**
១៧- លោក	**ហាក់ ម៉េងហាប់**	១៨- លោក	**បេ ឈុនកាំង**
១៩- លោក	**អ៊ូង ចិន្តា**	២០- លោក	**ឃុន ឡាត់**
២១- លោក	**ស៊ឹម សុវណ្ណារិទ្ធ**	២២- លោក	**មុត វ៉ានី**

គ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោក	**អ៊ិន សុភាព**	២- លោក	**ទូច ស៊ាងឡុង**
៣- លោក	**កែវ រ័ត្នមុនី**	៤- លោក	**ព្រហ្ម យ៉ន**

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោកស្រី	**តាំង យូហ៊ាង**	២- លោកស្រី	**តាំង យូគាង**
៣- លោកស្រី	**លឹម ផល្លី**	៤- លោកស្រី	**គួច មុយជួង**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៥- លោកស្រី	**ឡៅ លីខេង**	៦- លោក	**លី ជីម**
៧- លោក	**ឆន ទិបុល**	៨- លោក	**កែវ សារ៉ាត់**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១-ព្រះគ្រូនរបតិន្ទេវ៉ា	**ទិត ឫណា**	២- លោកស្រី	**លឹម សុគន្ធីរ៉ា**
៣- លោកស្រី	**លឹម សុគន្ធ**	៤- លោកស្រី	**លឹម ដួងដាលីន**
៥- លោក	**លឹម សំអាន**	៦- លោក	**ឆាយ សារ៉េត**
៧- លោក	**ចេង សុធា**	៨- លោក	**ឈរ ប៉េងអាន**
៩- លោកស្រី	**ជៀម ពុទ្ធពិសី**	១០- លោក	**វណ្ណា សិភា**
១១- លោក	**សុខា រ៉ូយ**	១២- លោក	**ឆេង ម៉ិនឃឿន**
១៣- លោក	**សុខ សំអាត**	១៤- លោក	**រ័ត្ន សុវណ្ណបញ្ញា**
១៥- លោក	**ប្រាជ្ញហង្ស សេរីរិទ្ធ**		

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោក	**ឈុន ហេង**	២- លោក	**អ៊ុត ម៉េងឡុង**
៣- លោក	**ឡាំ ម៉ាលីស**	៤- លោក	**លឹម ប៉ោឃៀង**
៥- លោក	**ជិន ហុក**	៦- លោក	**ប៉េងច័ន្ទរស្មី**
៧- លោក	**ម៉ិច បុរិចលនា**	៨- លោក	**អ៊ឹង ហុងខួន**
៩- លោកស្រី	**សុភក្តិ ពុទ្ធារ័ត្ន**	១០- លោក	**ថៃ បូរិទ្ធ**
១១- លោក	**គួន គន្ធា**	១២- លោក	**ប៉ែន សារិទ្ធ**

នស/រកត/១១២១/១៧៩០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២១

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១១២១/៧៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោធិសាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្ទេរ និងតែងតាំងមុខតំណែងលោកជំទាវ **ហូ សុវណ្ណារិកា** ពីរដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ មកជារដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

នរោត្តម សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/១១២១/១២៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឈិន ប៉ូលីន** (CHEN BOLIN) ជនជាតិ **ចិន** សញ្ជាតិ **ចិន** កើតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨១ នៅខេត្តហ៊្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.២១១១.៧៥៩៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានបង្ហាញត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤០៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១ .-

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៥ ៧៥៩ ០០០ ០០០ រៀល (ប្រាំបីលានប្រាំពីររយហាសិបប្រាំបួនលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងមហាផ្ទៃ (សន្តិសុខសាធារណៈ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

មាត្រា២ .-

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការទូទាត់ដល់ការតបណ្ដាញបញ្ជូនទិន្នន័យខ្សែកាបអុបទិច (Optical Fiber) ពីក្រុមហ៊ុនប្រតិបត្តិករទូរគមនាគមន៍ មកកាន់មជ្ឈមណ្ឌលទិន្នន័យអគ្គស្នងការដ្ឋាននគរបាលជាតិ, ការបន្តអាជ្ញាប័ណ្ណ Webint, និងសេវាគាំហែទាំប្រព័ន្ធ GI2-IMPACT និង GI2-S សម្រាប់រាវរកទីតាំងទូរស័ព្ទចល័ត (Find Direction) ដែលភ្ជាប់ប្រើដោយប្រព័ន្ធអ៊ិនធឺណេត។

មាត្រា៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១១រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១២ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់
គណៈកម្មាធិការពិសេសតាមដានការអនុវត្តកម្មវិធីសកម្មភាព
នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

សម្រេច
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ត្រូវបានបង្កើតគណៈកម្មាធិការពិសេសតាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ ដែលសរសេរជាអក្សរកាត់ថា **គ.អ.ស.អ.ប.អ.** ដើម្បីជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការតាមដាន និងការពន្លឿនការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

ជំពូកទី២
សមាសភាពរបស់គ.អ.ស.អ.ប.អ.

មាត្រា២.-

គ.អ.ស.អ.ប.អ.មានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងផែនការ	ប្រធាន
- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល	អនុប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ១រូប	អនុប្រធាន
- រដ្ឋលេខាធិការក្រសួងផែនការ១រូប	អនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងទេសចរណ៍១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា១រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ១រូប	សមាជិក
- តំណាងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនប្រចាំនៅកម្ពុជា១រូប	សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការ	សមាជិក
- តំណាងសង្គមស៊ីវិល	អ្នកសង្កេតការណ៍។

ក្រៅពីសមាសភាពខាងលើ **គ.អ.ស.អ.ប.អ.** អាចមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធតាមការចាំបាច់។ សមាសភាពជាក់ស្តែងនៃ**គ.អ.ស.អ.ប.អ.**ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ជំពូកទី៣
តួនាទីនិងភារកិច្ចរបស់គ.អ.ស.អ.ប.អ.

មាត្រា៣.-

គ.អ.ស.អ.ប.អ.មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ជួយរាជរដ្ឋាភិបាលក្នុងការអនុវត្តឱ្យសម្រេចបាននូវការប្ដេជ្ញាចិត្តដែលកម្ពុជាបានសន្យានៅក្នុងសន្និសីទទីក្រុងណៃរ៉ូប៊ីនៃសាធារណរដ្ឋកេនយ៉ា ឆ្នាំ២០១៩ ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា
- ផ្ដួចផ្ដើមនិងលើកសំណើជូនរាជរដ្ឋាភិបាល ក្នុងការរៀបចំនិងកែសម្រួលគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីសកម្មភាពនិងគោលនយោបាយជាតិនានាឆ្លើយតបទៅនឹងសេចក្ដីសម្រេចរបស់សន្និសីទអន្តរជាតិទីក្រុងណៃរ៉ូប៊ីស្ដីពីប្រជាជននិងអភិវឌ្ឍន៍
- ផ្ដល់វេទិកានិងការតម្រង់ទិសឱ្យមានការឯកភាពគ្នាពាក់ព័ន្ធទៅនឹងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យមានការឆ្លើយតបនឹងអាទិភាពសំខាន់ៗនៃក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍
- សម្របសម្រួលជាមួយនឹងស្ថាប័ននីតិប្បញ្ញត្តិ ក្រសួងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនានា សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីធានាឱ្យមានសង្គតិភាពរវាងផែនការអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍តាមវិស័យ ផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និងអាទិភាពរបស់ដៃគូអភិវឌ្ឍនានា ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមករវាងសកម្មភាពនិងយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍
- ពិនិត្យតាមដាននិងជំរុញការអនុវត្តកម្មវិធីសកម្មភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- កៀរគរប្រភពធនធានថវិកាពីដៃគូអភិវឌ្ឍនានានិងសង្គមស៊ីវិល ព្រមទាំងវិស័យឯកជន ដើម្បីនិរន្តរភាពការងាររបស់**គ.អ.ស.អ.ប.អ.**
- ចែករំលែកនិងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍ដល់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ
- រាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងអភិវឌ្ឍន៍ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍សកម្មភាពប្រចាំឆមាសនិងប្រចាំឆ្នាំរបស់ខ្លួនជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

ជំពូកទី៤
ការប្រព្រឹត្តទៅរបស់គ.អ.ស.អ.ប.អ.

មាត្រា៤.-

គ.អ.ស.អ.ប.អ.ត្រូវប្រជុំជាទៀងទាត់យ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីចាំបាច់ប្រធានអាចកោះប្រជុំជាវិសាមញ្ញបាន។

ក្នុងករណីប្រធានអវត្តមានឬករណីចាំបាច់ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ឱ្យដឹកនាំការប្រជុំជំនួស។

មាត្រា៥.-

ប្រធាន**គ.អ.ស.អ.ប.អ.**មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ តំណាងក្រសួង ស្ថាប័ន ឥស្សរជន អាជ្ញាធរមូលដ្ឋាន ឬដៃគូអភិវឌ្ឍនានា ដើម្បីចូលរួមប្រជុំតាមការចាំបាច់។

អនុប្រធាននិងសមាជិកនៃ**គ.អ.ស.អ.ប.អ.**ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានឬអនុប្រធានណាម្នាក់តាមការប្រគល់សិទ្ធិរបស់ប្រធាន។

មាត្រា៦.-

គ.អ.ស.អ.ប.អ.មានសិទ្ធិបង្កើតគណៈកម្មការអន្តរក្រសួងតាមការចាំបាច់ក្នុងក្របខ័ណ្ឌនៃការងារប្រជាជននិងអភិវឌ្ឍន៍ ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន**គ.អ.ស.អ.ប.អ.**។

មាត្រា៧.-

គ.អ.ស.អ.ប.អ.ត្រូវបង្កើតគណៈកម្មាធិការប្រជាជននិងអភិវឌ្ឍន៍រាជធានី ខេត្ត ដែលមានអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន អមដោយអនុប្រធាននិងសមាជិកមួយចំនួនតាមការចាំបាច់។ ប្រធានមន្ទីរផែនការរាជធានី ខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍។

គណៈកម្មាធិការប្រជាជននិងអភិវឌ្ឍន៍រាជធានី ខេត្ត មានមន្ទីរផែនការរាជធានី ខេត្ត ជាលេខាធិការដ្ឋាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រជាជននិងអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន**គ.អ.ស.អ.ប.អ.**។

មាត្រា៨.-

គ.អ.ស.អ.ប.អ.មានអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការ ជាលេខាធិការដ្ឋាន។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ ជាប្រធានលេខាធិការដ្ឋាន។

ប្រធានលេខាធិការដ្ឋានមានសិទ្ធិប្រើមន្ត្រីអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

ប្រធាន**គ.អ.ស.អ.ប.អ.**អាចកំណត់អំពីតួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋានតាមសេចក្ដីសម្រេចរបស់ប្រធាន។

មាត្រា៩.-

គ.អ.ស.អ.ប.អ.មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងផែនការ ដើម្បីដំណើរការការងាររបស់ខ្លួន។

ជំពូកទី៥

ប្រភពធនធានរបស់គ.អ.ស.អ.ប.អ.

មាត្រា១០.-

ថវិកាចំណាយសម្រាប់ដំណើរការរបស់លេខាធិការដ្ឋាននៃ**គ.អ.ស.អ.ប.អ.** និងរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រជាជននិងអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវបានគាំទ្រដោយថវិកាជាតិទៅតាមលទ្ធភាពថវិកាប្រចាំឆ្នាំក្នុងក្របខ័ណ្ឌនៃថវិការបស់ក្រសួងផែនការនិងថវិកាមន្ទីរផែនការរាជធានី ខេត្ត។

មាត្រា១១.-

គ.អ.ស.អ.ប.អ.មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់នូវធនធាននិងមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត តាមនីតិវិធីច្បាប់ជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា១២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៣រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ២១៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១ .-

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣ ៣២៩ ២០០ ០០០ រៀល (បីបីលានបីរយម្ភៃប្រាំបួនលានពីររយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

មាត្រា២ .-

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភកងកម្លាំងនគរបាលការពារ និងផ្គត់ផ្គង់ប្រេងឥន្ធនៈក្នុងយុទ្ធនាការការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០២១។

មាត្រា៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥១៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា១. បំពាក់មេដាយ**ការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការចំនួន១៥៩រូប នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមាននាយនាមខាងក្រោម៖

ក-មេដាយ**មាសការងារ**

១-	លោកស្រី	ឃឹម ផល្លា	អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
២-	លោក	សេក មុនី	អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ
៣-	លោក	ប៊ុត ចាន់ធី	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៤-	លោក	ងួន រតនា	អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តសៀមរាប

៥-	លោក	សេន សុខគា	អនុប្រធានមន្ទីរសង្គម កិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តតាកែវ
៦-	លោកស្រី	ស៊ិន ពុំ	ប្រធានការិយាល័យ នៃនាយកដ្ឋានសុខុមាលភាពកុមារ
៧-	លោក	ហេង សុភ័ក្រមុន្នីរ័ត្នរង្សី	ប្រធានការិយាល័យ នៃវិទ្យាស្ថានជាតិសង្គមកិច្ច
៨-	លោកស្រី	ភន គានី	អនុប្រធានមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
៩-	លោកស្រី	កើត ពៅ	ប្រធានការិយាល័យបេឡាជាតិអតីតយុទ្ធជន
១០-	លោក	ម៉ី សារឿន	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តតាកែវ
១១-	លោក	លី ស៊ិនណារ៉ា	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តតាកែវ

ខ-មេដាយ**ប្រាក់អាចារ**

១-	លោក	ម៉ី យឿន	អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម
២-	លោក	យឹន ហុងឆាត់	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៣-	លោក	វ៉ាន់ សារ៉ាវុធ	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៤-	លោក	យន់ កល្យាណ	ប្រធានការិយាល័យពិធីការ និងទំនាក់ទំនងសាធារណៈនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៥-	លោកស្រី	ផេង ពិសី	អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៦-	លោកស្រី	គង់ សារ៉េត	អនុប្រធានការិយាល័យនៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់
៧-	លោក	សុខ វិណ្ណា	អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប
៨-	លោក	យឹម កំសាន្ត	ប្រធានការិយាល័យនៃនាយកដ្ឋានផែនការ ស្ថិតិ និងសរុប
៩-	លោកស្រី	ថោ ពៅ	ប្រធានមណ្ឌលបុរីទារក និងកុមារជាតិ
១០-	លោកស្រី	ម៉ែន ផល្លា	ប្រធានការិយាល័យ នៃនាយកដ្ឋានសុខុមាលភាពកុមារ
១១-	លោកស្រី	សៅ សំភ័ស	ប្រធានការិយាល័យរដ្ឋបាលសុំកូនអន្តរប្រទេស
១២-	លោកស្រី	ថេម ពិសី	ប្រធានការិយាល័យរដ្ឋបាលសុំកូនអន្តរប្រទេស

១៣- លោកស្រី ម៉ម ដាណែត អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

១៤- លោក អៀម សុផល អនុប្រធានផ្នែក នៃអគ្គលេខាធិការក្រុមដ្ឋានប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

១៥- លោកស្រី ប៊ុន ចាន់រស្មី ប្រធានការិយាល័យក្រុមការងារថ្នាក់ជាតិពហុវិស័យ ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ

១៦- លោក ចាន់ ឡាយហ៊ាង ប្រធានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាភូមិភាគខេត្តបាត់ដំបង

១៧- លោក ដួង ច័ន្ទដារ៉ា ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ធំ

១៨- លោកស្រី អ៊ុង ហុកសៀវ អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ធំ

១៩- លោក ងៀវ ម៉េងលាង ប្រធានការិយាល័យបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ធំ

២០- លោកស្រី ឡាយ សុថារី អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ធំ

២១- លោក មឿន សុគុណ ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តសៀមរាប

គ-មេដាយ**សំរិទ្ធការងារ**

១- លោកស្រី អ៊ូ ម្លិះ មន្ត្រីមូលនិធិជនពិការ

២- លោក ហ្វូត សុធា អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ចាម

៣- លោកស្រី កែវ សុខុម ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ចាម

៤- លោក កៅ គឿន អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកោះកុង

៥- លោក អ៊ុង សុភាព អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកោះកុង

៦- លោកស្រី នេត និមល អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកែប

៧-	ប្រុស	ប៊ុន ប៉ែរ	អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តរតនគិរី
៨-	លោកស្រី	ឯក សុធា	អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តស្ទឹងត្រែង
៩-	លោកស្រី	សៀន ចាន់ថៃ	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទាខេត្តស្ទឹងត្រែង
១០-	លោក	លាក់ ផុន	អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឧត្តរមានជ័យ
១១-	លោក	ស៊ុន ចាន់គ្រឹះស្នា	ប្រធានការិយាល័យនៃអគ្គាធិការដ្ឋាន
១២-	លោក	ថុល ថាន	ប្រធានការិយាល័យនៃអគ្គាធិការដ្ឋាន
១៣-	លោកស្រី	ព្រំ ឆដាវី	អនុប្រធានការិយាល័យនៃអគ្គាធិការដ្ឋាន
១៤-	លោក	លី ស័ក្កា	មន្ត្រី នៃអគ្គាធិការដ្ឋាន
១៥-	លោកស្រី	ង៉ិល ធានី	អនុប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
១៦-	លោកស្រី	ម៉ៅ សុភណ្ណារី	អនុប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
១៧-	លោកស្រី	ជៀន វ៉ាន់ថា	អនុប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
១៨-	លោកស្រី	ប៉ូ សៀមុី	អនុប្រធានការិយាល័យបុគ្គលិកនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
១៩-	លោក	វុធ ពីសី	មន្ត្រីនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
២០-	លោកស្រី	ឡាយ គន្ធា	មន្ត្រីនៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
២១-	លោកស្រី	សុខ ភារី	ប្រធានការិយាល័យនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
២២-	លោក	គាប់ជិន ស៊ីដែត	អនុប្រធានការិយាល័យនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
២៣-	លោកស្រី	អ៊ុន សុខលីម	អនុប្រធានការិយាល័យនៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់
២៤-	លោកស្រី	នួន រំដួល	អនុប្រធានការិយាល័យនៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់

២៥-	លោកស្រី	ហួរ ដារីន	អនុប្រធានការិយាល័យ
២៦-	លោកស្រី	លាង សាទិត្យា	អនុប្រធានការិយាល័យ
២៧-	លោកស្រី	ជ្រុន ច័ន្ទពិសី	មន្ត្រី
២៨-	លោក	នាវ វណ្ណឌី	ប្រធានការិយាល័យនៃនាយកដ្ឋានសុខុមាលភាពសង្គម
២៩-	លោកស្រី	អ៊ិន អង្គផល្លា	អនុប្រធានការិយាល័យនៃនាយកដ្ឋានសុខុមាលភាពសង្គម
៣០-	លោក	អេង សុភ័ក្រ្គ	អនុប្រធានការិយាល័យនៃនាយកដ្ឋានសុខុមាលភាពសង្គម
៣១-	លោក	បាន ភ័រុធ	ប្រធានការិយាល័យ នៃនាយកដ្ឋានសុខុមាលភាពកុមារ
៣២-	លោក	ចាន់ រូដារុធ	ប្រធានការិយាល័យ នៃនាយកដ្ឋានសុខុមាលភាពកុមារ
៣៣-	លោក	យឹម សំអាត	អនុប្រធានការិយាល័យ នៃនាយកដ្ឋានសុខុមាលភាពកុមារ
៣៤-	លោកស្រី	បាន ស៊ីនួន	អនុប្រធានការិយាល័យ នៃនាយកដ្ឋានសុខុមាលភាពសង្គម
៣៥-	លោកស្រី	ជា កន្និកា	អនុប្រធានការិយាល័យ នៃនាយកដ្ឋានសុខុមាលភាពសង្គម
៣៦-	លោកស្រី	ច័ន្ទ សុភ័ក្តកញ្ញា	មន្ត្រីនៃនាយកដ្ឋានសុខុមាលភាពសង្គម
៣៧-	ប្រុស	សោម ជំនោរ	អនុប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ
៣៨-	លោកស្រី	អ៊ុំ ណៃគីម	មន្ត្រីនៃនាយកដ្ឋានសុខុមាលភាពជនពិការ
៣៩-	លោកស្រី	ហ៊ាង សុម៉ាលី	មន្ត្រីនៃនាយកដ្ឋានសុខុមាលភាពជនពិការ
៤០-	លោក	អ៊ឹង ចាន់តុលា	មន្ត្រីនៃនាយកដ្ឋានយុវនីតិសម្បទា
៤១-	លោក	ចាន់ ផនប៊ុនណៃល	អនុប្រធានការិយាល័យ នៃនាយកដ្ឋានយុវនីតិសម្បទា
៤២-	លោក	ផុល សាភា	មន្ត្រីនៃនាយកដ្ឋានយុវនីតិសម្បទា
៤៣-	លោក	ស្រេ ស្រ៊ី	មន្ត្រីនៃនាយកដ្ឋានយុវនីតិសម្បទា
៤៤-	លោកស្រី	ឈន សុគី	ប្រធានការិយាល័យនៃនាយកដ្ឋានអតីតយុទ្ធជន

៤៥-	លោក	យុន ចាន់ថន	ប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង
៤៦-	លោក	តាំង ម៉េងគុយ	អនុប្រធានការិយាល័យគណនេយ្យ
៤៧-	លោក	អ៊ិន សាខួន	អនុប្រធានការិយាល័យគណនេយ្យ
៤៨-	លោក	មាស សំណាង	អនុប្រធានដេប៉ាតឺម៉ង់នៃវិទ្យាស្ថានជាតិសង្គមកិច្ច
៤៩-	ឯកឧត្តម	ស្រី ចាន់	អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
៥០-	លោក	វ៉ន កុយ	ប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
៥១-	លោក	ឯម ចន្ថា	អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
៥២-	លោកស្រី	ផូ សុម៉ាឡែន	អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
៥៣-	លោកស្រី	ញ៉ឹក បូរីន	អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
៥៤-	លោកស្រី	ហុងហ៊ាង ស៊ីថេត	មន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
៥៥-	លោក	សុខ សុវណ្ណរិទ្ធ	អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
៥៦-	លោកស្រី	ឡុង សោភា	ប្រធានការិយាល័យ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
៥៧-	លោក	អៀត សីហា	អនុប្រធានការិយាល័យនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
៥៨-	លោក	អៀង ភាព	អនុប្រធានការិយាល័យនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
៥៩-	លោក	ផាន្នី កិត្តិគុណ	អនុប្រធានការិយាល័យនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
៦០-	លោកស្រី	ប៉ុក វិសាល	អនុប្រធានការិយាល័យនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
៦១-	លោកស្រី	ហៃ សុផារី	មន្ត្រីនៃបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

៦២-	លោកស្រី	គង់ ម៉ុច	អនុប្រធានការិយាល័យនៃមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
៦៣-	លោកស្រី	គង់ វណ្ណៈ	មន្ត្រីនៃមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន
៦៤-	ប្រុស	ជុន សីហា	ប្រធានការិយាល័យនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ
៦៥-	លោកស្រី	ជិន លីដា	អនុប្រធានការិយាល័យក្រុមការងារថ្នាក់ជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ
៦៦-	លោកស្រី	មូលសែម អមរង្សី	មន្ត្រីនៃមូលនិធិជនពិការ
៦៧-	លោកស្រី	អ៊ិន ដាលី	អនុប្រធានការិយាល័យ នៃមូលនិធិជនពិការ
៦៨-	លោកស្រី	សៅ ធីតា	មន្ត្រីនៃមូលនិធិជនពិការ
៦៩-	លោក	ប្រាក់ ចំរើន	ប្រធានការិយាល័យ នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ
៧០-	លោក	ពិក បូរ៉ា	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ
៧១-	លោក	សៅ សម្បត្តិ	អនុប្រធានការិយាល័យសុខុមាលភាពកុមារនិងយុវនីតិសម្បទា
៧២-	លោកស្រី	ស៊ឹម សូនម៉ាលីដែត	អនុប្រធានការិយាល័យសុខុមាលភាពសង្គម និងប្រឆាំងការជួញដូរមនុស្ស
៧៣-	លោក	យុង យុត្តានីន	អនុប្រធានការិយាល័យសុខុមាលភាពសង្គម និងប្រឆាំងការជួញដូរមនុស្ស
៧៤-	លោកស្រី	ភិន គន្ធា	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ
៧៥-	លោកស្រី	នាង ឯកវ៉ានិត	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ
៧៦-	លោក	លឹម បញ្ញាវ៉ាឈុន	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ
៧៧-	លោក	ឈឹន វណ្ណៈ	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ

៧៨-	លោក	វង្ស ចំណាន	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាខេត្តកណ្តាល
៧៩-	លោកស្រី	អឿ ម៉ារ៉ានី	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកណ្តាល
៨០-	លោក	អ៊ុម ពុទ្ធាឫទ្ធី	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ស្ពឺ
៨១-	លោក	ជាវ យីម	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ស្ពឺ
៨២-	លោកស្រី	សោម មុំ	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ស្ពឺ
៨៣-	លោក	ទ្រី វេងស្រេង	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកំពង់ស្ពឺ
៨៤-	លោក	ម៉ី ដារ៉ាស៊ី	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ស្ពឺ
៨៥-	លោក	មៅ ពុទ្ធា	ប្រធានការិយាល័យ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តស្វាយរៀង
៨៦-	លោកស្រី	ដៃ សុផាន្នី	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តស្វាយរៀង
៨៧-	លោកស្រី	ចាន់ សុភត្រា	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តស្វាយរៀង
៨៨-	ប្រុស	ប៉ុល ចាន់ថាន	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទាខេត្តកំពង់ឆ្នាំង
៨៩-	លោក	ឈុន សារ៉ែន	អនុប្រធានការិយាល័យ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ឆ្នាំង
៩០-	លោកស្រី	ហ៊ុំ សោភ័ណ្ឌ	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តពោធិ៍សាត់
៩១-	លោក	សួន ជីវ៉ា	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តពោធិ៍សាត់
៩២-	លោក	ជា ហៃ	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តពោធិ៍សាត់

ស្ត

៩៣-	លោក	ប៉ែន ពិសិដ្ឋ	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង
៩៤-	លោកស្រី	ដួង គឹមធៀង	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង
៩៥-	លោក	សុខ ធារ៉ា	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង
៩៦-	លោក	គា សុគន្ធ	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង
៩៧-	លោកស្រី	ហុង សុប៊ុនដាលីន	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង
៩៨-	លោក	លី វណ្ណី	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង
៩៩-	លោក	សុង ម៉ុម	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង
១០០-	លោកស្រី	យូ ទីនី	មន្ត្រីនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបាត់ដំបង
១០១-	លោកស្រី	ម៉ី សុធី	អនុប្រធានការិយាល័យ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ចាម
១០២-	លោក	ដួង ជេដ្ឋា	មន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ចាម
១០៣-	លោកស្រី	យ៉េង ចាន់ធន	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តប៉ៃលិន
១០៤-	លោកស្រី	យ៉ាន់ សាវ	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តប៉ៃលិន
១០៥-	លោកស្រី	ថាំង គឹមរីន	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពត
១០៦-	លោកស្រី	អ៊ឹង ម៉ាលីស្សា	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពត
១០៧-	លោក	ស៊ឹម សេរីវុណ្ឌ	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពត

១០៨-	លោកស្រី	សួន ស៊ីនេង	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រចេះ
១០៩-	លោកស្រី	ផាត់ ផាន់នី	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រចេះ
១១០-	លោកស្រី	ឈាវ មុំ	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តក្រចេះ
១១១-	លោក	ស ធីតា	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តត្បូងឃ្មុំ
១១២-	លោក	កាន់ សុផាត	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តត្បូងឃ្មុំ
១១៣-	លោក	ផាន សុខម៉ៅ	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តត្បូងឃ្មុំ
១១៤-	លោកស្រី	ចេង ចាន់ធឿន	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រៃវែង
១១៥-	លោក	សែម សាម៉ន	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រៃវែង
១១៦-	លោក	អ៊ូម បណ្ឌិត	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រៃវែង
១១៧-	លោកស្រី	ពួយ ចំរើន	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រៃវែង
១១៨-	លោកស្រី	ជា សូនីតា	អនុប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកែប
១១៩-	លោក	កែវ សុភាព	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តរតនគិរី
១២០-	លោក	សុខ សំណាង	អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តរតនគិរី
១២១-	លោក	ឡៃញ ធំ	ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ចាមខេត្តឧត្តរមានជ័យ

១២២- លោក យ៉ាន់ សុរចនា ប្រធានការិយាល័យនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តកំពង់ចាមខេត្តឧត្តរមានជ័យ

មាត្រា២.. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥១៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការ តែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

សម្រេច

មាត្រា១. បំពាក់មេដាយ**ការងារ** តាមលំដាប់ថ្នាក់ជូនអ្នករាជការចំនួន ៦៥រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មាសការងារ**

១-	លោក	និន្ទ មនោ	អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត
២-	លោកស្រី	អ៊ាង សារិ	ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តក្រចេះ
៣-	លោក	ហ៊ាង សុផល	ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តត្បូងឃ្មុំ
៤-	លោកស្រី	ហួត សុវណ្ណាវត្ត	ប្រធានការិយាល័យផែនការ និងសារពើភ័ណ្ឌ
៥-	លោក	ប៊ុន ធឿន	អនុប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តឧត្តរមានជ័យ
៦-	លោកស្រី	និន សុខនី	អនុប្រធានការិយាល័យរដ្ឋបាលសរុប
៧-	លោក	ហ៊ុយ ចំរើន	សមាជិកទទួលបន្ទុកផ្នែករដ្ឋបាលខេត្តកំពង់ស្ពឺ

៨- លោក ជា ប៊ុនរិទ្ធិ៍ សមាជិកទទួលបន្ទុកហិរញ្ញវត្ថុខេត្តកណ្ដាល

ខ-មេដាយ**ប្រាក់ភាខារ**

១- លោក ពេជ្រ រ៉ាវី អនុប្រធាននាយកដ្ឋានរដ្ឋបាល

២- លោក លន់ ជំនិត អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត

៣- លោក គុជ រាជរាម អនុប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត

៤- លោកស្រី ជាង កុល្លីដា អនុប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត

៥- លោក ទិត ចាន់ដារ៉ា អនុប្រធាននាយកដ្ឋានរដ្ឋបាល

៦- លោក ហេង ម៉េងហុង អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

៧- លោកស្រី ទិ សុវិដា ជំនួយការ ឯកឧត្តម មាន សទិ សមាជិក គ.ជ.ប

៨- លោក លី រតនា ជំនួយការ សមាជិក គ.ជ.ប និងជាប្រធានការិយាល័យសវនកម្មទី៣

៩- លោក ហាយ រិទ្ធីសោភ័ណ្ឌ ជំនួយការ សមាជិក គ.ជ.ប និងជាអនុប្រធានការិយាល័យរដ្ឋបាលសរុប

១០- លោក អ៊ុន សុភា ជំនួយការ គ.ជ.ប ជាប្រធានការិយាល័យរដ្ឋបាលសរុប

១១- លោក ឈឹម ចាន់ធឿន ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកំពង់ចាម

១២- លោកស្រី ហែម បញ្ញា ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តតាកែវ

១៣- លោក ទូច វិសាល ប្រធានការិយាល័យសម្របសម្រួលកិច្ចការសេវាកម្មច្បាប់ និងបច្ចេកទេស

១៤-លោក សុកុល: ពល:ឡូរ៉ង់ ប្រធានការិយាល័យសម្របសម្រួលការងារបោះឆ្នោតបណ្តុះបណ្តាល និងព័ត៌មាន

១៥-លោក គង់ កោសល្យ ប្រធានការិយាល័យអប់រំ ស្រាវជ្រាវ និងផ្សព្វផ្សាយ

១៦- លោកស្រី ប៊ុត បូរី ប្រធានការិយាល័យផែនការ និងប្រតិបត្តិការ

១៧- លោក វណ្ណ សុខាភីរម្យ ប្រធានការិយាល័យបច្ចេកទេស និងគ្រប់គ្រងទិន្នន័យស្ថិតិ

១៨- លោកស្រី គុន កល្យាណ ប្រធានការិយាល័យទំនាក់ទំនងសាធារណៈជាតិ អន្តរជាតិ

១៩- លោកស្រី ផាន់ ណារ៉េតកន្និកា ប្រធានការិយាល័យត្រួតពិនិត្យ និងហិរញ្ញកិច្ច

២០- លោក សែត សុខសីហា ជំនួយការ អគ្គលេខាធិការ និងជាអនុប្រធានការិយាល័យ សម្របសម្រួលការងារបោះឆ្នោត បណ្តុះបណ្តាល និងព័ត៌មាន

២១- លោក ព្រំ គីមធួន អនុប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកំពង់ស្ពឺ

២២- លោក ជា សុភឿន អនុប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តកំពង់ធំ

២៣- លោក នួន សុវណ្ណឌិច អនុប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តតាកែវ

២៤- លោកស្រី ចំរើន អវត្ដា លេខាធិការ ឯកឧត្តម ហ៊ីង ធីឫទ្ធិ សមាជិក គ.ជ.ប

២៥- លោក ភា ស៊ីវ៉ាឌី អនុប្រធានការិយាល័យរដ្ឋបាលសរុប

២៦- លោក មាន់ ស៊ិនសារិនវិចិត្រ សមាជិកទទួលបន្ទុករដ្ឋបាលខេត្តកំពង់ឆ្នាំង

២៧- លោក ប៊ុន ម៉េងស្រ៊ា សមាជិកទទួលបន្ទុករដ្ឋបាលខេត្តរតនគិរី

២៨- លោក គុន សំបឿន សមាជិកទទួលបន្ទុកហិរញ្ញវត្ថុខេត្តរតនគិរី
២៩- លោក ភិន ស៊ីផូ សមាជិកទទួលបន្ទុករដ្ឋបាលខេត្តកោះកុង
៣០- លោក ស៊ី វុទ្ធី សមាជិកទទួលបន្ទុកប្រតិបត្តិការខេត្តស្ទឹងត្រែង
៣១- លោក គង់ វង្សី មន្ត្រីទទួលបន្ទុកការងារបុគ្គលិក
៣២- លោក ទៀ សហ្សាត មន្ត្រីទទួលបន្ទុកគ្រប់គ្រងសន្តិសុខ
៣៣- លោក ប៊ុម សុរិន្ទធា មន្ត្រីទទួលបន្ទុកគ្រប់គ្រងសន្តិសុខ
៣៤- លោក ខាត់ ខាន់ មន្ត្រីត្រួតពិនិត្យឃ្លាំង
៣៥- លោក នីន ពៅ មន្ត្រីត្រួតពិនិត្យឃ្លាំង
៣៦- លោក ញ៉ឹក ចាន់ដារ៉ា ការីការងាររដ្ឋបាល
៣៧- លោក គុល សារឿត ការីការងាររដ្ឋបាល
៣៨- លោក ចាន់ កុសល ការីការងាររដ្ឋបាល
៣៩- លោក ឃិន ម៉ូដាវីន ការីការងាររដ្ឋបាល
៤០- លោក លុក ហុងលី ការីការងាររដ្ឋបាល
៤១- លោកស្រី ញ៉ែម ណារុន ការីការងាររដ្ឋបាល
៤២- លោក ទុន ផាន់នី ការីការងាររដ្ឋបាល
៤៣- លោក សុខ សំ ការីការងាររដ្ឋបាល
៤៤- លោក ប៉ុល ទិត ការីការងាររដ្ឋបាល
៤៥- លោក សៅ សិទ្ធិ ការីការងាររដ្ឋបាល
៤៦- លោក ម៉ា ស៊ីថា ការីការងាររដ្ឋបាល
៤៧- លោក ផន សារ៉ែន ការីការងាររដ្ឋបាល
៤៨- លោក មៀង សុខហ៊ន់ ការីការងាររដ្ឋបាល

គ-មេដាយ**សំរឹទ្ធភាពរខោរ**

១- លោក សេម សារ៉ុម អនុប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ
២- លោក នួន ច័ន្ទរិទ្ធ សមាជិកទទួលបន្ទុកប្រតិបត្តិការខេត្តព្រះវិហារ
៣- លោក ជា អ៊ាមហ៊ុង សមាជិកទទួលបន្ទុកហិរញ្ញវត្ថុខេត្តពោធិ៍សាត់
៤- លោកស្រី ខេង សិរីនិមល សមាជិកទទួលបន្ទុកហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ
៥- លោកស្រី ឃិន សម្ផស្ស សមាជិកទទួលបន្ទុកហិរញ្ញវត្ថុខេត្តកំពត
៦- លោក ផាត សាវិន សមាជិកទទួលបន្ទុកប្រតិបត្តិការខេត្តប៉ៃលិន
៧- លោក ឃឹម សុធា សមាជិកទទួលបន្ទុករដ្ឋបាលខេត្តត្បូងឃ្មុំ
៨- លោក ង៉ែត ចាន់ដារ៉ា សមាជិកទទួលបន្ទុកប្រតិបត្តិការខេត្តមណ្ឌលគិរី

៩- លោកស្រី កង កុលវិសាខា មន្ត្រីត្រួតពិនិត្យ និងហិរញ្ញកិច្ច

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥១៩ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១. បំពាក់មេដាយ**សំរឹទ្ធការងារ** ជូនមន្ត្រីចំនួន ១២រូបនៃពន្ធនាគារខេត្តព្រះវិហារ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

១- វរអគ្គានុរក្សថ្នាក់លេខ៣ ជឹម ឌីឡុច	អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តព្រះវិហារ
២- វរអគ្គានុរក្សថ្នាក់លេខ៣ សាន គុយហេង	អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តព្រះវិហារ
៣- វរអគ្គានុរក្សថ្នាក់លេខ៣ ព្រំ ឈន	ប្រធានផ្នែក នៃពន្ធនាគារខេត្តព្រះវិហារ
៤- វរអគ្គានុរក្សថ្នាក់លេខ៣ ប៊ុន រស់	ប្រធានផ្នែក នៃពន្ធនាគារខេត្តព្រះវិហារ
៥- វរអគ្គានុរក្សថ្នាក់លេខ៣ ហាយ ច័ន្ទរិទ្ធ	ប្រធានផ្នែក នៃពន្ធនាគារខេត្តព្រះវិហារ
៦- អនុរក្សថ្នាក់លេខ១ ខឹម រតនី	ប្រធានផ្នែក នៃពន្ធនាគារខេត្តព្រះវិហារ
៧- វរអគ្គានុរក្សថ្នាក់លេខ៣ វ៉ាង វុទ្ធី	អនុប្រធានផ្នែក នៃពន្ធនាគារខេត្តព្រះវិហារ
៨- វរអគ្គានុរក្សថ្នាក់លេខ៣ មាស សារិន	អនុប្រធានផ្នែក នៃពន្ធនាគារខេត្តព្រះវិហារ
៩- អនុរក្សថ្នាក់លេខ៣ ម៉ន ភក្តី	មន្ត្រី នៃពន្ធនាគារខេត្តព្រះវិហារ
១០- អនុរក្សថ្នាក់លេខ៣ ឆុង សីហា	មន្ត្រី នៃពន្ធនាគារខេត្តព្រះវិហារ

១១- អនុរក្សថ្នាក់លេខ៣ ស៊ឹម សរ មន្ត្រី នៃពន្ធនាគារខេត្តព្រះវិហារ

១២- អនុរក្សថ្នាក់លេខ៣ ស៊ឹម សេដ្ឋី មន្ត្រី នៃពន្ធនាគារខេត្តព្រះវិហារ

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២០.អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលរង នៃគណៈអភិបាលខេត្តពោធិ៍សាត់ សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម៖

១-លោក **សាយ សុជាតិ** ឋាននន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលរង នៃគណៈអភិបាលខេត្តពោធិ៍សាត់

២-លោក **គិត សុផា** ឋាននន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ជាអភិបាលរង នៃគណៈអភិបាលខេត្តពោធិ៍សាត់។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩២១ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **ហ្វូត ហៃ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២២.អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការចំនួន ០៣រូប ជាអភិបាលរង នៃគណៈអភិបាលខេត្តកោះកុង សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម៖

១-លោក **ស្រេង ហុង**	ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១	ជាអភិបាលរងខេត្ត
២-លោក **សុខ សុទ្ធី**	ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦	ជាអភិបាលរងខេត្ត
៣-លោក **អ៊ុក គំគ្រា**	ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២	ជាអភិបាលរងខេត្ត។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២១✓

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩២៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **ស្រេង សុខា** ឋាននន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៣ ឲ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកបាណន់ ខេត្តបាត់ដំបង។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១២៣ សសរ

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានីភ្នំពេញ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- យោងសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ប្រការ១ .-

ត្រូវបានតែងតាំង ឯកឧត្តម **ប៉ា សុជាតិវង្ស** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ជា**អនុប្រធាន**ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**រាជធានីភ្នំពេញ** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រការ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្ត សេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៣ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០២១

តប.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១១ សសរ

សេចក្ដីសម្រេច

ស្ដីពី

ការបញ្ចូលក្របខ័ណ្ឌពលទាហានថ្មី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

ប្រការ១ : អនុញ្ញាតឱ្យក្រសួងការពារជាតិ បញ្ចូលក្របខ័ណ្ឌ ពលទាហានថ្មី ក្នុងកងយោធពលខេមរភូមិន្ទ ចំនួន ៣៤៣ (បីរយសែសិបបី) នាក់ សម្រាប់បំពេញក្របខ័ណ្ឌឱ្យកងឯកភាព ចំណុះបញ្ជាការដ្ឋានអង្គរក្ស អគ្គបញ្ជាការដ្ឋាន ។

ប្រការ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១[illegible]......សហវ.ក

ប្រកាស
ស្តីពី
ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ
ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

សាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៨២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្ត អង្គភាពថវិកា
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្ត អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១២៨២ សហវ.ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការ អង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៧៩៦ សហវ.ប្រក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការ អង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៧៤៧ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការ អង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការ អង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

ត្រូវបានប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ សម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុលើឥណទានថវិកាប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០២១ តទៅ ជូនប្រធានអង្គភាពថវិកាថ្នាក់កណ្តាល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចតទៅ÷

១. អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២. អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ

៣. អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

៤. អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

៥. អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា

៦. អគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

៧. អគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

៨. អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល

៩. អគ្គាធិការ នៃអគ្គាធិការដ្ឋាន

១០. អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

១១. នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១២. អគ្គនាយក នៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។

ប្រការ២.-

ឥណទានថវិការបស់អង្គភាពថវិកានីមួយៗ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយក្នុងឆ្នាំសារពើពន្ធត្រូវបានកំណត់នៅក្នុងប្រកាសស្ដីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំសារពើពន្ធ។

ឥណទាននេះត្រូវបែងចែកតាមមាតិកាកម្មវិធី (អនុកម្មវិធី និងចង្កោមសកម្មភាព) និងមាតិកាសេដ្ឋកិច្ច (ក្រុម ប្រភេទ ជំពូក គណនី និងអនុគណនី) ដែលត្រូវបានកំណត់ក្នុងសៀវភៅថវិកាកម្មវិធីឆ្នាំសារពើពន្ធសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៣.-

អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវសម្របសម្រួលរួមលើថវិកាគាំទ្រកិច្ចដំណើរការរបស់ថ្នាក់ដឹកនាំក្រសួង។

អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងពេលបំពេញមុខងារជាអាណាប័កផ្ទេរសិទ្ធិ ត្រូវប្រើប្រាស់រដ្ឋលេខាធិការ...

ប្រការ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៥.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៩៥ សហវ.ប្រក

ប្រកាស
ស្តីពី
ការបង្កើតសារមន្ទីរគយ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 - Fax: 855-23-427 798

- បានឃើញប្រកាសលេខ ១៤៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

ត្រូវបានបង្កើត "**សារមន្ទីរគយ**" មានទីតាំងក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលស្ថិតនៅអគារលេខ៦-៨ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ប្រការ២.-

សារមន្ទីរគយ គឺជាមជ្ឈមណ្ឌលសម្រាប់÷

- ប្រមូលផ្តុំ ចុះបញ្ជីសារពើភណ្ឌ រក្សាទុក រៀបចំឡើងវិញ ផ្សព្វផ្សាយ និងដាក់តាំងបង្ហាញនូវឯកសារកេរ្តិ៍ដំណែល ស្នាដៃ និងវត្ថុនានា ដែលទាក់ទងនឹងសាវតារ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងការងារប្រមូលចំណូល សម្រួលពាណិជ្ជកម្ម បង្ការនិងបង្ក្រាបបទល្មើស និងការពារសង្គមជាតិ
- ឱ្យសាធារណជនទូទៅទស្សនា សិក្សាស្រាវជ្រាវ និងស្វែងយល់អំពីប្រវត្តិ តួនាទី ភារកិច្ច និងសមិទ្ធផលការងាររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមទាំងផ្សព្វផ្សាយអប់រំបង្កើនចំណេះដឹងនិងលើកកម្ពស់វប្បធម៌នៃការបង់ពន្ធក្នុងវិស័យគយនិងរដ្ឋាករ។

ប្រការ៣.-

សារមន្ទីរគយមានរចនាសម្ព័ន្ធជាការិយាល័យក្រោមឱវាទរបស់សាលាជាតិគយ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ សារមន្ទីរគយត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ។

ប្រការ៤.-

សាលាជាតិគយ ត្រូវដឹកនាំនិងគ្រប់គ្រងសារមន្ទីរគយ ដូចខាងក្រោម÷

- គ្រប់គ្រងកិច្ចដំណើរការទូទៅ និងសុវត្ថិភាពនៃសារមន្ទីរគយ
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ និងវត្ថុតាំងបង្ហាញ ដែលស្ថិតក្រោមការប្រើប្រាស់និងគ្រប់គ្រងរបស់សារមន្ទីរគយ
- ស្រាវជ្រាវ ចងក្រង វាយតម្លៃ និងជ្រើសរើសនូវឯកសារ កេរ្តិ៍ដំណែល ស្នាដៃ និងវត្ថុនានា សម្រាប់ដាក់តាំងបង្ហាញ ឬដកចេញពីសារមន្ទីរគយ
- រៀបចំផែនការអភិវឌ្ឍន៍សារមន្ទីរគយ ស្របតាមការវិវឌ្ឍរីកចម្រើននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមទាំងសេដ្ឋកិច្ច និងសង្គម

- លើកឡើង និងចាត់ចែងអនុវត្តគម្រោងជួសជុល និងកែលម្អសំណង់អគារ និងប្លង់សារមន្ទីរគយ សម្រាប់ការដាក់តាំងបង្ហាញឱ្យបានសមរម្យ និងធានាសុវត្ថិភាព
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសប្បុរសជន ដើម្បីកៀរគរវត្ថុសម្រាប់ដាក់តាំងបង្ហាញ និងធនធានសម្រាប់អភិវឌ្ឍនិងទ្រទ្រង់សារមន្ទីរគយ
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ប្រការ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៦.-

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១១រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៩៩៦ សហវ.ប្រក

ប្រកាស

ស្តីពី

វិធាននិងនីតិវិធីនៃការព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយចំពោះទំនិញ នាំចេញ-នាំចូលល្មើសកម្មសិទ្ធិបញ្ញា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះ មានគោលបំណងពង្រឹងប្រសិទ្ធភាព នៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាតាមរយៈការកំណត់វិធាន និងនីតិវិធីសម្រាប់ព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយនូវរាល់ការនាំចេញ- នាំចូលទំនិញដែលល្មើសច្បាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយចំពោះទំនិញនាំចេញ- នាំចូលល្មើសកម្មសិទ្ធិបញ្ញា ដែលពាក់ព័ន្ធនឹងម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។

ជំពូកទី ២
ការស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយលើទំនិញសង្ស័យល្មើសកម្មសិទ្ធិបញ្ញា

ប្រការ ៣.-

ម្ចាស់កម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជីស្របច្បាប់ ឬភ្នាក់ងារតំណាងស្របច្បាប់ អាចដាក់ពាក្យស្នើសុំទៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឱ្យផ្អាកជាបណ្តោះអាសន្ននូវការបំពេញបែបបទបញ្ចេញទំនិញពីគយលើទំនិញសង្ស័យថាល្មើសកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលដោយបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

អ្នកដាក់ពាក្យស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយបណ្តោះអាសន្នចំពោះទំនិញដូចខាងលើ ត្រូវបង់កម្រៃចំនួន ១,០០០,០០០ រៀល (មួយលានរៀលគត់)។

ប្រការ ៤.-

អ្នកដាក់ពាក្យស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយបណ្ដោះអាសន្នចំពោះទំនិញដែលសង្ស័យល្មើសកម្មសិទ្ធិបញ្ញា ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម៖

ក. ច្បាប់ចម្លងនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

ខ. ការរៀបរាប់ដ៏ល្អិតល្អន់ពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ ព្រមទាំងទំនិញគំរូដែលបានចុះបញ្ជីស្របច្បាប់ ប្រសិនបើមានសំណូមពរ

គ. លិខិតថ្លែងបញ្ជាក់ពីហេតុផលជាមូលដ្ឋាន និងភស្តុតាងជាក់ស្ដែងថាទំនិញទាំងនោះល្មើសកម្មសិទ្ធិបញ្ញា

ឃ. ឯកសារបញ្ជាក់លក្ខណៈពិសេសដែលអាចវិនិច្ឆ័យភាពខុសគ្នារវាងទំនិញពិត និងក្លែងក្លាយ

ង. លិខិតបញ្ជាក់អត្តសញ្ញាណ ដូចជាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

ច. លិខិតផ្ទេរសិទ្ធិពីម្ចាស់កម្មសិទ្ធិបញ្ញា ប្រសិនបើពាក្យស្នើសុំនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ

ឆ. បង់កម្រៃរដ្ឋបាលដូចក្នុងកថាខណ្ឌ ២ នៃប្រការ ៣។

ប្រការ ៥.-

ក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំដូចក្នុងប្រការ ៤ នៃប្រកាសនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរថាទទួលយកទៅចាត់ការ ឬបដិសេធនូវសំណើសុំនេះ។

ប្រការ ៦.-

ក្នុងរយៈពេលមិនលើសពី ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការឆ្លើយតបទៅម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាងពីការទទួលយកការស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយទៅចាត់ការ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវជូនព័ត៌មានទៅម្ចាស់ទំនិញអំពីការព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយរួមទាំងឈ្មោះ និងអាសយដ្ឋាននៃអ្នកស្នើសុំព្យួរ និងត្រូវអញ្ជើញម្ចាស់ទំនិញឬតំណាង និងម្ចាស់កម្មសិទ្ធិបញ្ញាឬតំណាង ដើម្បីចូលរួមត្រួតពិនិត្យរូបវន្តទំនិញ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទត្រួតពិនិត្យរូបវន្តទំនិញ។ ក្នុងរយៈពេលមិនលើសពី ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបាននូវការអញ្ជើញម្ចាស់ទំនិញឬតំណាង និងម្ចាស់កម្មសិទ្ធិបញ្ញាឬតំណាង ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរពីការចូលរួមត្រួតពិនិត្យរូបវន្តទំនិញនេះ មកអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាវិញ។

មុនពេលទំនិញត្រូវបានធ្វើការត្រួតពិនិត្យរូបវន្ត ក្នុងករណីម្ចាស់កម្មសិទ្ធិបញ្ញាឬតំណាងដកពាក្យស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយ ឬមិនបានបញ្ជាក់ពីការចូលរួមត្រួតពិនិត្យរូបវន្តទំនិញតាមរយៈពេលកំណត់នេះ ឬពុំមានការស្នើចាត់វិធានការបណ្ដោះអាសន្នដើម្បីពន្យារការព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយ ឬពីអាជ្ញាធរដែលបានប្រគល់សិទ្ធិផ្សេងទៀតនោះ ពាក្យស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយត្រូវទុកជាមោឃៈ ហើយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចបន្តនីតិវិធីគយតាមបទប្បញ្ញត្តិជាធរមាន ។

ជំពូកទី ៣
ការត្រួតពិនិត្យទំនិញសង្ស័យល្មើសកម្មសិទ្ធិបញ្ញា

ប្រការ ៧ .-

មន្ត្រីគយនិងរដ្ឋាករ ត្រូវធ្វើការត្រួតពិនិត្យរូបវន្ត និងត្រូវផ្ទៀងផ្ទាត់រវាងព័ត៌មានក្នុងពាក្យស្នើសុំព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយ ជាមួយឯកសារពាក់ព័ន្ធ ដើម្បីស្វែងរកភស្តុតាងនានានៃការល្មើសកម្មសិទ្ធិបញ្ញា។ ការត្រួតពិនិត្យរូបវន្តនេះ ត្រូវមានការចូលរួមពីម្ចាស់ទំនិញ ឬតំណាង និងម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាង និងអាចស្នើសុំកិច្ចសហការពីស្ថាប័នឯកទេសផ្សេងទៀតដើម្បីចូលរួមត្រួតពិនិត្យរូបវន្ត។

ម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាង និងម្ចាស់ទំនិញ ឬតំណាង អាចនាំមកជាមួយនូវឯកសារពាក់ព័ន្ធបន្ថែមទៀតដើម្បីប្រើប្រាស់តាមការចាំបាច់។

ក្នុងករណីម្ចាស់ទំនិញ ឬតំណាង អវត្តមានដោយគ្មានមូលហេតុ ការត្រួតពិនិត្យរូបវន្តនឹងត្រូវបន្តអនុវត្តស្របតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ ៨ .-

ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនោះអាចល្មើសកម្មសិទ្ធិបញ្ញា មន្ត្រីគយនិងរដ្ឋាករ ត្រូវបន្តព្យួរទុកជាបណ្តោះអាសន្ននូវនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ។ បន្ទាប់មក ម្ចាស់កម្មសិទ្ធិបញ្ញាឬតំណាង ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីសម្រេចថាទំនិញនេះពិតជាល្មើសកម្មសិទ្ធិបញ្ញា និងមានចំណាត់ការបន្តលើទំនិញល្មើសនេះ ហើយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវសម្របសម្រួលសហការបញ្ជូនសំណុំរឿងពាក់ព័ន្ធទៅតុលាការផងដែរ។

ក្នុងករណីមិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាទំនិញនេះជាទំនិញល្មើសកម្មសិទ្ធិបញ្ញា ការបំពេញបែបបទបញ្ចេញទំនិញពីគយនឹងត្រូវអនុវត្តបន្តតាមបទប្បញ្ញត្តិជាធរមាន។

ប្រការ ៩ .-

ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីតុលាការ ម្ចាស់ទំនិញ ឬតំណាង និងម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាង អាចស្នើសុំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដកយកទំនិញគំរូដើម្បីពិនិត្យនិងវិភាគ ក្នុងគោលបំណងបញ្ជាក់ឱ្យដឹងថាទំនិញនោះល្មើស ឬមិនល្មើសកម្មសិទ្ធិបញ្ញា ដោយត្រូវប្រគល់ទំនិញគំរូនោះមកវិញក្រោយពី បានបញ្ចប់ដំណើរការពិនិត្យ និងវិភាគ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចដកយកទំនិញគំរូក្នុងពេលណាមួយដើម្បីធ្វើការពិសោធន៍ ឬ ផ្ទៀងផ្ទាត់ជាក់ស្តែង ក្នុងករណីចាំបាច់។

ជំពូកទី ៤
ការអនុវត្តសិទ្ធិរបស់មន្ត្រីគយនិងរដ្ឋាករដោយពុំមានការស្នើសុំពីម្ចាស់កម្មសិទ្ធិបញ្ញា (Ex Officio)

ប្រការ ១០ .-

មន្ត្រីគយនិងរដ្ឋាករ មានសមត្ថកិច្ចអាចព្យួរទុកការបំពេញបែបបទបញ្ចេញទំនិញពីគយ ក្នុងអំឡុងពេលនាំចេញឬនាំចូល នៅពេលដែលទទួលបាននូវភស្តុតាងបឋម ឬមានហេតុផលសមរម្យដែលអាចសង្ស័យថាល្មើសកម្មសិទ្ធិបញ្ញាពាក់ព័ន្ធនឹងម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់

ប្រហែល។ ការព្យួរទុកការបំពេញបែបបទបញ្ចេញទំនិញពីគយនេះ អាចធ្វើក្នុងរង្វង់រយៈពេលត្រឹម ១០(ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

ប្រការ ១១ .-

បន្ទាប់ពីព្យួរទុកការបំពេញបែបបទបញ្ចេញទំនិញពីគយតាមបញ្ញត្តិប្រការ ១០ ខាងលើនេះ មន្ត្រីគយនិងរដ្ឋាករ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់ទំនិញ ឬតំណាង និងម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាងដើម្បីផ្តល់ព័ត៌មាន ឬមកផ្ទៀងផ្ទាត់ទំនិញ ក្នុងរយៈពេលមិនលើសពី ០៧(ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីមិនមានភស្តុតាងគ្រប់គ្រាន់បង្ហាញថាទំនិញនោះល្មើសកម្មសិទ្ធិបញ្ញា នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយនឹងត្រូវអនុវត្តបន្តតាមបទប្បញ្ញត្តិជាធរមាន។ មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបានលើកលែងពីការទទួលខុសត្រូវឬបន្ទុកនានា នៅពេលដែលសកម្មភាពទាំងនោះត្រូវបានអនុវត្តឡើងដោយសុចរិតភាព។

ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់បង្ហាញថាទំនិញនោះល្មើសកម្មសិទ្ធិបញ្ញា អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចបន្តការព្យួរទុកការបំពេញបែបបទបញ្ចេញទំនិញពីគយ ហើយម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាង មានរយៈពេល១០(ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីផ្តួចផ្តើមដំណើរការដោះស្រាយវិវាទ ឬចំណាត់ការតាមផ្លូវតុលាការ ដោយត្រូវតម្កល់និមុត្តិធានាតាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ប្រសិនបើម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាង មិនផ្តួចផ្តើមដំណើរការដោះស្រាយវិវាទ ឬចំណាត់ការតាមផ្លូវតុលាការ នោះមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចត្រូវមានចំណាត់ការបន្តតាមផ្លូវតុលាការ។

ជំពូកទី ៥
និមុត្តិធានា និងសន្និធិ

ប្រការ ១២ .-

ក្នុងករណីអនុវត្តតាមបញ្ញត្តិនៃប្រការ ៦ និង ប្រការ ១១ នៃប្រកាសនេះ មន្ត្រីគយនិងរដ្ឋាករមានសិទ្ធិតម្រូវឱ្យម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាង តម្កល់និមុត្តិធានាមានតម្លៃស្មើនឹង ៣០% នៃតម្លៃទំនិញនាំចេញនាំចូល ដើម្បីការពារការខាតបង់ដល់ម្ចាស់ទំនិញ ឬតំណាង និងអាជ្ញាធរមានសមត្ថកិច្ច។

ការតម្កល់និមុត្តិធានាត្រូវធ្វើឡើង នៅពេលដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាឆ្លើយតបជាលាយលក្ខណ៍អក្សរថាទទួលយកពាក្យស្នើព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយទៅចាត់ការ។

ក្នុងករណីទំនិញដែលត្រូវព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយ ជាប្រភេទទំនិញឆាប់ខូចគុណភាព ម្ចាស់កម្មសិទ្ធិបញ្ញា ឬតំណាង ត្រូវតម្កល់និមុត្តិធានាបន្ថែមតាមស្ថានភាពជាក់ស្តែង។

និមុត្តិធានាខាងលើ ត្រូវរក្សាទុក ក្នុងគោលបំណងទូទាត់ការខូចខាតដល់ម្ចាស់ទំនិញ ឬតំណាង និងអាជ្ញាធរមានសមត្ថកិច្ច ឬបង្វែរសងទៅម្ចាស់កម្មសិទ្ធិបញ្ញាវិញ។

ប្រការ ១៣ .-

ទំនិញដែលជាកម្មវត្ថុ នៃការព្យួរទុកការបំពេញបែបបទបញ្ចេញទំនិញពីគយ ត្រូវរក្សាទុកនៅទីកន្លែងដែលមានការអនុញ្ញាតពីមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច។

ជំពូកទី ៦
អន្តរប្បញ្ញត្តិ

ប្រការ ១៤ .-

ម្ចាស់ទំនិញ ឬតំណាងមានសិទ្ធិដាក់បណ្តឹងមកអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឬតុលាការមានសមត្ថកិច្ច ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ ១៥ .-

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចេញសេចក្តីណែនាំចាំបាច់នានាស្តីពីការគ្រប់គ្រងទំនិញនាំចេញ-នាំចូលល្មើសកម្មសិទ្ធិបញ្ញា សំដៅធានាឱ្យមានតម្លាភាព និងប្រសិទ្ធភាពនៃការអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ។

ជំពូកទី ៧
អវសានប្បញ្ញត្តិ

ប្រការ ១៦ .-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១៧ .-

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១ រោច ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- សភាពាណិជ្ជកម្មកម្ពុជា

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១៧ *"ដើម្បីអនុវត្ត"*
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥៥ សហវ.ប្រក

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងថ្នាក់ដឹកនាំ នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាជានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៦១៥ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបង្កើតបន្ថែមគណនី និងអនុគណនីនៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

ប្រការ១ ._

ត្រូវបានតែងតាំងលោក ហែន ចាន់ណាវុធ ឋានៈ អនុប្រធានការិយាល័យគណនេយ្យ ទទួលបន្ទុកជាភ្នាក់ងារបើកផ្តល់នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ២ ._

លោក ហែន ចាន់ណារុធ ជាភ្នាក់ងារបើកផ្តល់ ត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជដៃគូ ដើម្បីទទួលមូលនិធិសម្រាប់អនុវត្តការបើកផ្តល់បៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាល ទីប្រឹក្សា ប្រាក់បេសកកម្ម ប្រាក់បុរេប្រទាន និងប្រាក់ចំណាយពិធីបុណ្យរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ប្រការ៣ ._

បែបបទនៃការអនុវត្តការបើកផ្តល់បៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាល ទីប្រឹក្សា ប្រាក់បេសកកម្ម ប្រាក់បុរេប្រទាន និងប្រាក់ចំណាយពិធីបុណ្យត្រូវបានកំណត់ដោយបទដ្ឋានគតិយុត្តដោយឡែក។

ប្រការ៤ ._

ភ្នាក់ងារបើកផ្តល់ មានការទទួលខុសត្រូវដោយផ្ទាល់ខ្លួន និងអំពីប្រាក់កាសនិងចំពោះមូលនិធិទាំងអស់ដែលបានទទួល និងបានបើកផ្តល់។

ប្រការ៥ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៦ ._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធ អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃទី ... ខែ ... ឆ្នាំ... ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ... ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

